សារព័ត៌មាន ខ្មែរផុស ស.រ.អ

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Issue 168 Jan.2th. - 22nd. 2015

Free

មាតិការឿង

១-ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៤)................០២
២-អាចនឹងស្រក់ទឹកភ្នែកដឹងខ្លួន: បន្ទាប់ពីឃើញសារ...០៤
៣-ឆ្នាំថ្មី, រដ្ឋរ៉ូដអាយឡិនបញ្ចុះថ្លៃបង់ពន្ធ...............០៩
៤-ស្គាល់.................................................១៤
៥-វប្បធម៌សន្តានៅព្រះរាជាចក្រកម្ពុជា................១៦
៦-ជំរឿនប្រជាជនឆ្នាំ១៩៩៨ បានឱ្យដឹងថា.............១៨
៧-ព្រះសមណ: ស៊ីន ហាយ ជានរណា?..............១៩

Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

### បទសម្ភាសន៍ជាមួយដំណាងរដ្ឋថ្មី លោក វ៉ាឌី ម៉ម

**ដោយ ពិន សំខុន**

នៅមួយសប្តាហ៍មុនធ្វើសច្ចាប្រណិធានចូលកាន់ដំណែងជាដំណាងរដ្ឋ (State representative) លោក វ៉ាឌី ម៉ម **តទៅទំព័រទី ០៤**



លោក វ៉ាឌី ម៉ម

## ទ្រង់រណឫទ្ធិ: ទៅហើយមកហ៊្វុនស៊ិនប៉ិចវិញ

សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បាន សម្រេចព្រះទ័យចូលធ្វើជាប្រធានគណបក្ស ហ៊្វុនស៊ិនប៉ិចឡើងវិញ ដោយមានការយាង ពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនេះ។ ទ្រង់ ជាប្រធានគណបក្សសង្គមរាស្ត្រាជាធិបតេយ្យ **តទៅទំព័រទី ១០**



ទ្រង់រណឫទ្ធិទទួលជាប្រធានហ៊្វុនស៊ិនប៉ិចនាឱកាសខួបព្រះជន្មា៧១ អ្នកម្នាង អ៊ុក ផល្លា ជាបរបាសិច្ឆើន Birthday ថ្វាយព្រះអង្គ

## ទៅលេងគ្រួសារនៅស្រុកបាយឆៅនាកម្ពុជាក្រោម (ភាគ៤បញ្ចប់)

**តពីលេខមុន**

ទោះជាមានកុម្មុយនិស្តក៏ដោយក្តី។

នៅពេលដែលប្តីខ្ញុំចេញមកភ្នំពេញមកការកូនប្រុសមួយទៀតនាថ្ងៃបន្ទាប់ ខ្ញុំនៅព្រៃនគរ ឬ"សាយគ្គន"ឯណោះ បន្តនាំម្តាយបង១នឹងក្មួយ១ ទៅទស្សនារមនីយដ្ឋាននានាឱ្យបានរីករាយនឹងភ្លក់រស់ជាតិជាទេសចរដំបូងបង្អស់ទៅតំបន់ថ្មី ដែលភាគច្រើនមិនដែលចេញពីស្រុកបាយឆៅទៅទីឆ្ងាយម្តងណាទេ ដូច្នេះជាឱកាសល្អសម្រាប់រៀនសូត្រពីជីវិតពិត១នឹងបង្កើនយកបទពិសោធន៍ថ្មី១សម្រាប់ផ្លាស់ប្តូ ឬជីវិតខ្លួនឯងពីកូនកសិករក្រីក្រផង ។ ព្រៃនគរមិនត្រឹមតែនាំមកនូវអនុស្សាវរីយនៃមហានគរខ្មែរដែលទេសចរថ្មីថ្មោងធ្លាប់ជាម្ចាស់ទឹកដីនៃតំបន់នោះតែប៉ុណ្ណោះទេ តែក៏ផ្តល់នូវសោភ័ណ្ឌភាពនៃវប្បធម៌ចិន-វៀតណាមដែលម្ចាស់ទឹកដីថ្មី គឺយួនឥឡូវគេចូលចិត្តឱ្យហៅថា"វៀតណាម"ជាងដែលប្រឹងប្រែងឆ្នៃ

**តទៅទំព័រទី ១១**



**I DO TAXES**



**ខ្ញុំទទួលធ្វើតាក់ជូនលោកអ្នក**

មានបទពិសោធន៍២៥ឆ្នាំ
យើងបម្រើធ្វើតាក់សម្រាប់បុគ្គលឯកជន
ខណ:ដែលលោកអ្នកប្រើពេលរង់ចាំ
ទាំងពេលយប់ និងចុងសប្តាហ៍ក្នុងខែធ្វើតាក់

Law Office of Thomas Stylianos
287 Appleton Street Lowell MA 01852
(978) 459-5000



**ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស**

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

# ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៤)

**តពីលេខមុន**

ដីធំទូលំទូលាយប្រកបដោយសួនច្បារថែទាំយ៉ាងហ្មត់ចត់ផ្ទះធំតូចសង់ជាបន្ទប់ច្រើនជាន់ក៏មានជាបន្ទប់ផ្ទះដាច់តែឯងក៏សម្បូរតែក្បាច់រចនានឹងតែងលំអរជាខ្មែរទាំងអស់ ហើយក៏មានផ្តល់ទាំងឆ្នេរខ្សាច់សមុទ្រសក្បុសនឹង"កាស៊ីណូ" ផ្ទាល់ខ្លួនផង។ ភ្ញៀវទាំងក្នុងនឹងមកពីក្រៅអាចចូលទៅបរិភោគម្ហូបចំណីឈ្ងុយឆ្ងាញ់រៀបចំប្រណីតទទួលភ្ញៀវកិរិតថ្នាក់ពលរដ្ឋឧត្តមមន្ត្រីតែតម្លៃអាចប្រជែងនឹងហាងនានាក្នុងក្រុងបានម្លោះហើយមានការចូលរួមទទួលភ្ញៀវមិត្តភ័ក្រ្តគ្រួសារខ្មែរបានច្រើនឱ្យមកភ្លក់រស់ជាតិ "ម្ហូបជីវិតអ្នកមាន"បាន ប៉ុន្តែតម្លៃនៃបន្ទប់វិញខ្ពស់ជាងនៅសណ្ឋាគារល្អៗឯទៀត ក្នុងក្រុងច្រើនផង។ ដោយសារសណ្ឋាគារតែមួយនេះ បានផ្តល់នូវកេរ្តិ៍ឈ្មោះជាក្រុងលំដាប់ទេសចរណ៍មានភ្ញៀវសំខាន់ៗនឹងអ្នករកស៊ីធំៗ បើរួមទាំងក្រុងឧស្សាហកម្មមួយផ្នែកទៀត ដែលសម្បូរដោយក្រុងកម្មករនឹងមុខរបរតូចតាចផង គេអាចផ្សងសំណាងមកនៅទីនោះរកគ្រប់គ្រាន់នឹងរស់បានច្រើនគ្នា ។

ក្រុងកំពុងសោមមិនជាធំទេ មើលតែបន្តិចក៏អស់ទៅហើយតែផ្ទៃសមុទ្រមើលទៅថ្លាឆ្វង់មើលដល់បាតទាក់ទាញយើងឱ្យបោះបង់ការកំសាន្តនៅសណ្ឋាគារប្រណិតនោះចោលទៅហែលទឹកនាប្រជុំកោះក្បែរច្រាំងសមុទ្រខ្មែរ នាពេលថ្ងៃទៅវិញ។



កោះខ្មែរដ៏កម្សត់ត្រូវគេទិញអស់ហើយ



រ៉ូមេអូត្រូវឪពុកសែងចេញដោយមុតជើងនឹងសត្វសមុទ្រ



ប៊ុណ្ណារ៉ូ ហែលទឹកខ្មែរជាលើកដំបូងជាមួយនឹងបងៗ

ក្នុង៣ថ្ងៃដែលយើងស្នាក់នៅកំពុងសោម យើងទៅកំសាន្តហែលទឹកសមុទ្រអស់២ថ្ងៃទៅហើយស្តាប់អ្នកម្ចាស់កាណូតដរ ដែលថ្ងូរពីអនាគតការងារចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួនថា ជាការផ្សងព្រេងពីព្រោះកោះខ្មែរគេយកផង គេទិញផង មិនអាចនាំភ្ញៀវទៅដល់ឆ្នេរសមុទ្រ កោះបានទៀតទេ តម្រូវឱ្យទូកសំចតកណ្តាលសមុទ្រហើយភ្ញៀវកំសាន្តដោយហែលទឹកក្បែរទូកដែលខ្លួនជិះនោះទៅក្រោមការទទួលខុសត្រូវនៃម្ចាស់ទូកតែម្នាក់ប៉ុណ្ណោះមិនខុសគ្នាពីសំដីម្ចាស់កាណូតនៅកែបទេ ពួកគេនឹកថា នៅបន្តិចទៀត ពេលដែលកោះ ទាំងនោះរៀបចំរួចហើយកាណូតដរទាំងនោះនឹងពុំអាចសំចតនៅក្បែរកោះបានទៀតទេ។ ទោះជាយ៉ាងនេះក្តីយើងរស់នៅសម្រាប់

**តទៅទំព័រទី ០៦**


# ការិយាល័យច្បាប់ ហ្វង់ស៊ីស្កូ ជេ.រ៉ូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រូសា



Andrew ´Bunna´ Taing, Esq.
មេធាវី ប៊ុណ្ណា អែនធ្រូ តាំង

Law Office of:
FRANCISCO J. ROSA
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

## ខូម៉ែរ សិប្បកម្មឆ្លាក់សំណាកក្រានីត
## COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials — ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្នូរផ្តេកមានឆ្លាក់សំរិទ្ធលើថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER
Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

# មេធាវីធីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្ដាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្ដីប្រពន្ធ ឬគូរដណ្ដឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្ដីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

## តមកពីទំព័រទី ០១ បទសម្ភាសន៍ជាមួយតំណាងរដ្ឋថ្មី...

ដែលនឹងចូលក្នុងប្រវត្តិសាស្ត្រនៃជនជាតិខ្មែរទី១ បានកាន់មុខដំណែងនេះជាលើកដំបូងបង្អស់នៅសហរដ្ឋអាមេរិក លោកបានផ្តល់បទសម្ភាសន៍មួយដល់ ពិន សំខុន កាសែត "ខ្មែរផុសស.រ.អា." ដែលមានអត្ថន័យដូចតទៅ :

**ខ្មែរផុស ស.រ.អា.** ជំរាបសួរលោក វ៉ាឌី ម៉ម ! នៅមួយអាទិត្យទៀត លោកនឹងធ្វើសច្ចាប្រណិធានដើម្បីចូលទៅកាន់ដំណែងជាតំណាងរដ្ឋម៉ាសឈូសិតប្រចាំ សង្កាត់លេខ១៨នៃក្រុងឡូវែល

តើលោកមានសារអ្វីនឹងជម្រាបជូនទៅលោកអ្នកអានខ្មែរផុស ដែរឬទេ?

**វ៉ាឌី ម៉ម :** បាទជម្រាបសួរ! ជាបឋម ខ្ញុំសូមអរគុណលោក ពិន សំខុន ដែលបានមកធ្វើសម្ភាសន៍រូបខ្ញុំដោយផ្ទាល់ ។ ពាក្យដែលខ្ញុំចង់ផ្តាំផ្ញើរទៅបងប្អូនយើងដែលបានបោះឆ្នោតឱ្យខ្ញុំមានតែមួយទេ គឺសង្គមយើងត្រូវការឱ្យបងប្អូនយើងរួមគ្នា ដូច្នេះសូមឱ្យអ្នកបោះឆ្នោតនោះ ចេញមុខមកប្រាប់ខ្ញុំបន្ថែមទៀត ថាត្រូវការចង់បានអ្វីយើងនឹងធ្វើទាំងអស់គ្នាមិនមែនតែខ្ញុំម្នាក់ឯងទេ

**ខ្មែរផុសស.រ.អា.** អ្វីទៅដែលជាកម្មវិធីអទិភាពដែលលោកនឹងត្រូវធ្វើមុនគេនៅពេលដែលលោកចូលកាន់ដំណែង?

**វ៉ាឌី ម៉ម :** ខ្ញុំបានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាសន្តិសុខសាធារណៈខ្ញុំមានគម្រោងនឹងដាក់ឱ្យមានប្រព័ន្ធទាក់ទងមួយដែលនៅពេលមានអំពើឧក្រិដ្ឋណាមួយកើតឡើង គេអាចហៅទៅដល់ក្រុមប៉ូលិសបានភ្លាមធ្វើយ៉ាងនេះអាចផ្តល់ភាពកក់ក្តៅនឹងសន្តិសុខឡើងវិញ ដែលពីដើមនោះ ខ្មែរយើងមិនដឹងទៅរកជំនួយឯណាទេ! បញ្ហាចំបងមួយ



លោក វ៉ាឌី ម៉ម

ទៀតគឺបញ្ហាអប់រំ គឺយើងត្រូវរួបរួមមិនត្រឹមតែសហគមន៍ម្នាក់ឯងទេ ត្រូវពួតកម្លាំងជាមួយសាសន៍ដទៃក្នុងសហគមន៍ប្រគួតឱ្យបានថវិកាបន្ថែម ដើម្បីតម្លើងគុណភាពនៃសាលារៀនយើង ។

**ខ្មែរផុស ស.រ.អា.** មានលោកគ្រូខ្លះនិយាយថាមានការរើងអើងក្នុងការជ្រើសរើសបុគ្គលិកនៅម៉ាសឈូសិតនេះ ពុំមានខ្មែរជានាយកសាលាទេ ហេតុអ្វី? គ្មានអ្នកពូកែ ? ឬក៏មានការប្រកាន់?

**វ៉ាឌី ម៉ម:** ខ្ញុំមិនហ៊ានថាទេ តែយើងមានមនុស្សដូច រីទ្ធី អ៊ុង ជា"នាយករងសាលារៀន" តើគាត់មានចង់ធ្វើជានាយកដែរឬក៏អត់ ខ្ញុំក៏មិនដឹងដែរ តែស្ថានភាពវាប្តូរពីដើមយើងគ្មានដំណាងតាំងពី៣៣៥ឆ្នាំមក បងប្អូនបានបោះឆ្នោតឱ្យខ្ញុំពេលនេះឥឡូវយើងមានសម្លេងហើយក្រុងឡូវែលទាំងមូលគួរតែមានមោទនភាពពីសម្លេងនេះ ក្រឡេកទៅមើលទៅសហគមន៍ជនជាតិភាគតិចទាំងអស់សូម្បីតែពួក"ស្បានីស"វិញ ក៏ពុំមានដំណាងដែរ នេះគឺជាលើកដំបូងបង្អស់ហើយ ។

**ខ្មែរផុស ស.រ.អា.** នៅពេលដែលពលរដ្ឋកំពុងតែរីករាយនឹងជ័យជំនះរបស់លោកជាខ្មែរបានឈ្នះឆ្នោតនោះ មានព្រឹត្តិការណ៍មួយបានកើតឡើង គឺនៅពេលដែលលោកទៅធ្វើទស្សនកិច្ចនៅកម្ពុជាបន្ទាប់ពីបានជាប់ឆ្នោតភ្លាមមានការខឹងសម្បារនឹងលោកមានការទិទានដោយប្រើពាក្យមិនគប្បីជាច្រើនផង តើលោកមានដឹងដែរឬទេ ?

**វ៉ាឌី ម៉ម:** ខ្ញុំឥតបានដឹងផង ប្រហែលជាខ្ញុំរវល់ខ្លាំងពេក ។

**ខ្មែរផុសស.រ.អា.**ចុះលោកមានអានកាសែតខ្មែរផុសលេខចុងក្រោយនេះទេ? ចេញផ្សាយ១អាទិត្យហើយដែលមានជាសារចំពោះលោក ពីព្រោះខ្ញុំរកមិនជួប ។

**វ៉ាឌី ម៉ម:** ឥតបានមើលដែរ! តើអ្នកទិទានហ្នឹងមានចំនួនច្រើនប៉ុណ្ណា?

**ខ្មែរផុសស.រ.អា.**មានច្រើនមានគេនិយាយពេញក្រុង

**វ៉ាឌី ម៉ម:** ខ្ញុំគិតថា ប្រហែលជាមានមនុស្សមួយក្រុមនោះ មិនបានដឹងពីតួនាទីខ្ញុំ ខ្ញុំចង់ទៅណាក៏បាន ដូចលោកអីចឹង! ចង់ទៅស្រុកខ្មែរ ឬទៅទីណា ជាតួនាទីរបស់លោក! ដូចលោក សម រង្ស៊ី លោក អូបាម៉ា ចង់ទៅណាជាតួនាទីរបស់លោកទាំងនោះដែលត្រូវមានទំនាក់ទំនងនៅទីណាក៏បានមិនចាំបាច់គេបញ្ជាឱ្យធ្វើតាមទើបធ្វើនោះទេ...ជឿថាមានការខ្វះនូវចំណេះដឹងពីតួនាទីរបស់ខ្ញុំ ខ្ញុំចង់ជួបបុគ្គលនោះផ្ទាល់! ដល់ពេលមកវិញទៀត សួរថាតើមានបុគ្គលណាស្លាប់ដោយសារខ្ញុំឬទេ? ថាគ្មានទេ! ឡូវែលមានរលំហើយ ឬនៅ? ថាគ្មានទេ! ថាខ្ញុំទៅចូលគណបក្សណានៅស្រុកខ្មែរនោះហើយឬនៅ? ថាអត់ទេ! ខ្ញុំគ្មានបំរើគណបក្សណាទេ ខ្ញុំជាប់ឆ្នោតនៅឡូវែលខ្ញុំបំរើប្រជាពលរដ្ឋនៅឡូវែលតែប៉ុណ្ណោះ...

**ខ្មែរផុស ស.រ.អា.**នៅពេលបានដឹងរឿងនេះហើយដោយសារខ្ញុំក្តី ឬក៏នឹងបានដឹងនៅពេលក្រោយក្តី ខ្ញុំចង់ដឹងថា តើ វ៉ាឌី ម៉ម នៅតែបំរើសហគមន៍ទាំងមូល ឬក៏ទុកអ្នកដែលមិនសប្បាយចិត្តនឹងលោកមួយចំហៀងបំរើតែអ្នកណាដែលពេញចិត្ត?

**វ៉ាឌី ម៉ម:** តួនាទីរបស់ខ្ញុំ គឺបំរើមនុស្សទាំងអស់គ្នា ទោះជាអ្នកបានបោះឆ្នោត ឬក៏មិនបានបោះឱ្យខ្ញុំក្តី តែខ្ញុំមិនមែនបំរើមនុស្សតែ១នាក់ទេ មកប្រាប់ខ្ញុំថាឱ្យធ្វើដូច្នេះ ធ្វើដូច្នោះនោះ គឺខ្ញុំមិនមែនគោទេ គ្មាននរណាដាក់កន្ទុះខ្ញុំទេ...

**តទៅទំព័រទី ០៩**

# អាចស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន! បន្ទាប់ពីឃើញសារចុងក្រោយរបស់នារីអាកាសចរនៃយន្តហោះ AirAsia QZ8501







January ៣. ២០១៥

**បយ សុវណ្ណ**

**បរទេស:** រឿងរ៉ាវដ៏ក្តុកក្តួលក្នុងចិត្តមួយរបស់នារីអាកាសចរ និងក៏ជាជនរងគ្រោះម្នាក់នៃឧបទ្ទវហេតុគ្រោះថ្នាក់ធ្លាក់យន្តហោះ AirAsia QZ8501 កាលពីពេលថ្មីៗនេះ កំពុងតែធ្វើឱ្យមនុស្សជាច្រើនមានការចាប់អារម្មណ៍ និងសោកស្តាយចំពោះរូបនាងជាខ្លាំងបន្ទាប់ពីនាងបានបន្សល់ **តទៅទំព័រទី ១០**











# យន្តហោះដឹកភ្ញៀវទេសចរណ៍១គ្រឿងបានធ្លាក់ចុះក្នុងសមុទ្រនៃប្រទេសឥណ្ឌូនេស៊ី

**ដកស្រង់ដោយ : ថាច់ វណ្ណា**

យន្តហោះ អែរអេស៊ៀ Air Asia QZ85001 លេខ A320-200 ត្រូវបានធ្លាក់ចុះក្នុងសមុទ្រក្បែរកោះបរណេអូ (Borneo) នៃ



ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃអាទិត្យទី២៨ ធ្នូថ្មី១នេះ ដោយត្រូវប៉ះនឹងខ្យល់ព្យុះត្រង់ចន្លោះកណ្ដាលសមុទ្ររវាងប្រទេសឥណ្ឌូនេស៊ី និងសង្ហបុរីបណ្ដាលឱ្យមនុស្សស្លាប់ចំនួន១៦២នាក់ ក្នុងនោះមានជនជាតិអង់គ្លេសម្នាក់, ជនជាតិកូរ៉េខាងត្បូង៣នាក់ ជនជាតិឥណ្ឌូនេស៊ី១៥៥នាក់ នឹងមួយចំនួនទៀតជាជនជាតិសិង្ហបុរី និង ម៉ាឡេស៊ី, អ្នកបើកយន្តហោះជនជាតិបារាំង ។

-នេះជាយន្តហោះទី៣ ហើយក្នុងរយៈពេលមិនពេញមួយឆ្នាំដែលត្រូវបានធ្លាក់ និងបាត់ខ្លួន ដោយជាប់ទាក់ទិនក្រុមហ៊ុនដឹកជញ្ជូននៃប្រទេស ម៉ាឡេស៊ី, គ្រឿងម៉ាស៊ីនយន្តហោះ នោះបានផលិតផលចេញពីក្រុមហ៊ុន CFM អន្តរជាតិ, ជាក្រុមហ៊ុនបានរួមបញ្ចូល ជីអ៊ី (GE) General Electric នឹងក្រុមហ៊ុនសាហ្វ្រែន (Sapran) នៃប្រទេសបារាំង ដោយមានការកង្វះផ្ទៃកបច្ចេកទេសត្រួតពិនិត្យដោយខ្លួនឯងឱ្យបានទាន់ពេល ។

-កាលពីថ្ងៃ៨ ខែមិនា ២០១៤ ក្រុមហ៊ុន យន្តហោះម៉ាឡេស៊ី MH370 ត្រូវបាត់ខ្លួនក្នុងពេលធ្វើដំណើរពីទីក្រុងកូឡាឡាំពូទៅទីក្រុងប៉េកាំងប្រទេសចិនក្នុងនោះ មានភ្ញៀវទេសចរណ៍ចំនួន២៣៩នាក់ និងបុគ្គលិកអាកាសយានត្រូវបាត់ខ្លួនរហូតមកទល់សព្វថ្ងៃ ។



-បន្ទាប់មកក្រុមហ៊ុនយន្តហោះដដែលនេះ លេខ HM17 នៅថ្ងៃទី១៧ ខែកក្កដា ថ្មី១នេះ បានត្រូវបាញ់ធ្លាក់ទៅទៅលើប្រទេសយូក្រែន




បណ្ដាលឱ្យមនុស្ស២៩៨នាក់ក្នុងយន្តហោះធ្លាក់ស្លាប់គ្មានសល់ ។

-យន្តហោះ QZ8501 បានហោះកំពស់ ៣២.០០០ហ្វីតត្រូវនឹង៩.៧៥៣ម៉ែត្រ រួចបានស្នើសុំការអនុញ្ញាតិឱ្យបន្ថែមកំពស់ឡើងទៅដល់៣៨.០០០ហ្វីត ប៉ុន្តែគេពុំឃើញមានសញ្ញាបានទទួលការអនុញ្ញាតិឱ្យហោះខ្ពស់ដើម្បីផុតពីជំនោរខ្យល់ព្យុះនោះឡើយ ។

ស.រ.អា បានទៅចូលរួមក្នុងការស្វែងរកសាកសព និងកំទេចកំទីដែលនៅសេសសល់ រួមជាមួយ និងប្រទេសឥណ្ឌូនេស៊ី, សិង្ហបុរី,អូស្ត្រាលី, ម៉ាឡេស៊ី, និងកូរ៉េខាងត្បូង រួមទាំងអស់មាននាវាចំនួន៣០ និងយន្តហោះចំនួន២១ ដើម្បីធ្វើការស្រាវជ្រាវស្វែងរកសាកសពមកទល់ពេលនេះថ្ងៃទី៣១ ខែធ្នូ គេបានរកឃើញសាកសពចំនួន៧នាក់ក្នុងនោះមានប្រុស៤នាក់ និងស្រី៣នាក់ ។ បន្ទមកទៀតអ្វីដែលអ្នកស្រាវជ្រាវចង់បាននោះ គឺប្រអប់ខ្មៅទិន្នន័យ (Black Box) ពួកគេនៅមិនទាន់រកឃើញនៅឡើយ ព្រោះវាលិចចុះជ្រៅទៅបាតសមុទ្រពុំអាចឱ្យសញ្ញាមកលើអាកាសបាន ៕

ព័ត៌មានដកស្រង់ពីច្រើនប្រភព

**CNN,VOA,Reuters, Telegraph-UK,Huflington post, Providence,Jouruel**

**LOWELL JEWELRY &LOAN**
**ហាងឥណទាន និងគ្រឿងអលង្ការ**
**PAWNS UP TO $10,000**
**ទទួលបញ្ចាំរហូតដល់តម្លៃ $10.000**
Est. 1993
តាំងពីឆ្នាំ១៩៩៣

**Need instant Cash?**
**អ្នកត្រូវការលុយប្រញាប់?**
- We lend you more money for your gold for 10% lower interest rate compared to our competitors
- យើងខ្ញុំបញ្ចាំដោយយកការប្រាក់ចុះ១០%ថោកជាងគូរប្រជែងក្នុងទីផ្សារ មានការក្សាអាថិកំបាំងរបស់ភ្ញៀវ
- ការណាត់ជួបជាឯកជន សូមអញ្ជើញទូរស័ព្ទមកលេខខាងក្រោម និយាយភាសាអង់គ្លេស សុំជួបជាមួយគ្រីស **978-454-8877** ឬទាក់ទងតាម info@lowellpawn.com




អញ្ជើញមកហាងយើងខ្ញុំ មានបញ្ចុះតម្លៃសម្រាប់ថ្ងៃបុណ្យនឹងរបស់របរផ្សេងៗទៀតជាច្រើន តាមអាសយដ្ឋានដូចខាងក្រោម
24 Merrimack Street. Lowell, MA 01852

**978-454-8877**
Store Hours:
Monday – Friday: 10AM – 5PM
Sunday: 12PM – 5PM

## តមកទំព័រទី ០២ ដំណើរពីអាមេរិកទៅអាស៊ី...


ជួបលោកអនុប្រធានរដ្ឋសភា កឹម [illegible] [illegible] ទៅពី [illegible] និងហ៊ីឡារៃដេបហ្សៀ

បច្ចុប្បន្នកាលជូលទូកត្រឹមតែដំណើរគេអាចធ្វើ បានកំសាន្តត្រឹមតែគេអនុញ្ញាត្តិទេសចរ ដូចពួកយើងថ្ងៃនេះ គ្មានទឹកទៅដល់ការសង្គ្រោះបន្ទាន់ពីរអវត្តមាននៃសម្ព័ន្ធរដ្ឋបាលណាបានទេ។

វវល់កំសាន្តនឹងសមុទ្រមិនទាន់អស់ចិត្តផង ក៏ដល់ពេលត្រឡប់មកភ្នំពេញវិញទៅហើយ ស្តាយឱកាសសំរាកយ៉ាងរីករាយដែលមានតិចតួចពីការងារមួយឆ្នាំស្រាប់តែត្រូវឃ្លាតពីសមុទ្រខ្មែរទៅវិញ។


ចេញដំណើរពីសណ្ឋាគារសុខាក្រុងព្រះសីហនុ


[illegible]

ថ្ងៃស្អែកជាថ្ងៃត្រូវ ចេញដំណើរពីក្រុងកំពុងសោមទៅហើយ ដើម្បី រៀបចំខ្លួនទៅចូលគាល់ព្រះមហាក្សត្រ នាថ្ងៃទី ២៤ ដែលនៅតែប៉ុន្មានថ្ងៃទៀតសោះរំកិលកាន់តែជិត។

នៅលើផ្លូវជាតិលេខ៤ដែលជាផ្លូវ "ហាយវេយ" ខ្មែរដំបូងបង្អស់សង់ដោយអាមេរិកាំងជាជំនួយដល់កម្ពុជាតាំងពីមុនឆ្នាំ១៩៦០ ឯណោះនោះផ្លូវនេះ នៅតែមានប្រជាប្រិយដោយមានអ្នកប្រើប្រាស់ច្រើនហើយ នាបច្ចុប្បន្ននេះរដ្ឋអំណាចដាក់ឱ្យបង់លុយសម្រាប់អ្នកបើកបរលើផ្លូវនេះ ។ ក្រុមអ្នកធ្វើដំណើរយើងបានត្រឡប់មកភ្នំពេញវិញនៅលើផ្លូវជាតិលេខ៤នោះ តែខ្ញុំនៅចងចាំប្រវត្តិដ៏ច្រើននៃការសាងសង់ផ្លូវកាត់តាមព្រៃក្រាស់នឹងភ្នំខ្ពស់ៗជាលើកដំបូងបង្អស់ដោយគ្រឿងចក្រធំៗពណ៌លៀងរោទិ៍ឮខ្លាំងជាងក្របីទៅទៀតបើករាល់ថ្ងៃហុយដីទ្រលោមដោយជនស្បែកសមាឌធំៗគ្មានត្រូវការគូលីលីសែងកាប់ឆ្ការឬប្រើចបបែលដូចមុនៗទេ គេធ្វើថ្នល់នោះរាប់ឆ្នាំទំរាំសង់ចប់...ពេលនោះខ្ញុំនៅរៀនសាលាបឋមសិក្សាកំពុងស្ពឺ រស់នៅក្បែរផ្សារ ជាមួយបងស្រីបងថ្លៃ និងក្មួយៗរញ្ជៀវ ។ នៅតាមផ្លូវខ្ញុំចងចាំកំពូលភ្នំពេចនិលដែលគេនាំគ្នាទៅបន់ស្រន់ចងចាំភ្នំត្រពាំងក្រឡឹងកន្លែងដែលគេធ្លាប់យកអ្នកប្រឆាំងនឹងរដ្ឋាភិបាលសីហនុទៅបាញ់ចោល...កាត់តាមកំពុងស្ពឺ រកាធំ ថ្នល់ទទឹង អង់ស្នួល កន្លែងដែលអ្នកដំណើរតាមរថយន្តឈ្នួលទិញចំណីចំណុកក្នុងតំបន់ស្រស់ៗហូបកុំឱ្យឃ្លានតាមផ្លូវ ។ ចាប់ពីប្រមាណ២០គីឡូម៉ែត្រញនៅមាត់ទ្វារភ្នំពេញ នាពេលរសៀលចរាចរណ៍ផ្ដើមស្ទះដោយសារមានកម្មកររោងចក្ររាប់ម៉ឺននាក់ដែលចេញពីនឹងចូលទៅធ្វើការដោយសាររថយន្តធំៗដឹកជញ្ជូនកម្មករទាំងនោះ ដោយម៉ូតូ រ៉ឺម៉កម៉ូតូ អ្នកថ្មើជើងអ្នកជិះកង់នឹងអ្នកលក់ដូរច្រើនសន្ធឹកសន្ធាប់យ៉ាង គួរឱ្យភ្ញាក់ផ្អើល... ប៉ុណ្ណឹងហើយនៅមិនទាន់គ្រប់គ្រាន់ទៀត យើងបានសង្កេតឃើញរោងចក្រនៅតែផ្សាយត្រូវការរកអ្នកចូលមកធ្វើការបន្ថែមទៀតនៅឡើយ ។ **តទៅទំព័រទី ០៧**

MIYA ភោជនីយដ្ឋានម៉ី_យ៉ា
SUSHI & ASIAN CUISINE
Tel 978-323-7878 / Fax 978.323.7879
ស៊ូស៊ី និង ម្ហូបអាស៊ី
DINE-IN / TAKE-OUT / DELIVERY

អាហារពិសេសថ្ងៃត្រង់ Lunch Specials
ស៊ូស៊ី : Sushi $9.95
បាយកញ្ចប់ : Lunchbox $7.95
Entrees from Kitchen ម្ហូបក្លែមចេញពីផ្ទះបាយ
- Japanese • ម្ហូបជប៉ុន
- Malaysian • ម៉ាឡេស៊ី
- Thai • ម្ហូបថៃ
- Chinese • ម្ហូបចិន
Address :16 Merrimack Street
Lowell, MA 01852
www.MIYAasian.com
Catering - Beer & Wine
ការផ្គត់/ស្រា-បៀរ/ជូនដល់ផ្ទះ


CONWAY
INSURANCE AGENCY
រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :
ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខិខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

## តមកទំព័រទី ០២ ដំណើរពីអាមេរិកទៅអាស៊ី...

ចូលមកដល់ក្រុងភ្នំពេញ ទើបឃើញថា រដ្ឋបាលក្រុងភ្នំពេញបានខិតខំធ្វើផ្លូវថ្មីខ្វាត់ខ្វែង ធ្វើស្ពាន លើទឹកផង លើគោកផង ចាក់កៅស៊ូតាមផ្លូវធំ ឬតូចកៀនកោះ ដាក់រនាំងនៅគ្រប់កណ្ដាលផ្លូវធំៗ កុំឱ្យចរាចរទៅនឹងមកអាចលាយគ្នាបាន គឺដើម្បីបន្ធូរសម្ពាធចរាចរតែគង់មិនឈ្នះពលរដ្ឋភ្នំពេញហួសចំណុះចំនួនច្រើនលាននាក់ នឹងភាពមិនគោរពច្បាប់ចរាចរ នៃរថយន្ត ម៉ូតូ ម៉ូតូឌុប រ៉ឺម៉កម៉ូតូ ដែលចូលមកជំនួសស៊ីក្លូ បាត់ខ្លួន មិនដឹងទៅណាអស់ ។ រីឯកងប៉ូលីសចរាចរ យើងសង្កេតឃើញនៅគ្រប់បង្គោលភ្លើងស្តុបក្នុងក្រុង គឺមានចំនួនច្រើនមែនតែពុំមានមធ្យោបាយសម្រាប់ពង្រឹងច្បាប់ទេ ដូចជាគ្មានយានជំនិះសម្រាប់ប្រដេញ គ្មានវិទ្យុទាក់ទង គ្មានអាវុធ គ្មានការការគ្រប់គ្រង... ផ្ទុយទៅវិញ កងប៉ូលិសបង្ក្រាបបាតុករនៅវិមានឯករាជ្យកំពុងប្រឈមមុខពលរដ្ឋដែលខឹងសម្បារដោយសារខ្លួនបាត់បង់ផ្ទះសម្បែង គឺមានសម្ភារៈសឹកទំនើបមានរថពាសដែកធំតូចគាំទ្រមានខែលធំៗ ដំបងឆក់ មានមួកដែកគ្របមុខជិតកុំឱ្យគេស្គាល់ មានការហាត់ហ្វឹកហ្វឺន គ្រប់គ្រងវិន័យបានល្អណាស់ ។ ភ្លេចខ្លួនតែមួយភ្លែត រថយន្តបើសយើង ក៏មកដល់ទម្លាក់យើងនៅសណ្ឋាគារបែបបារាំងមួយក្បែរវិទ្យាល័យស៊ីសុវត្ថិ... សូបិន និងប៊ុណ្ណារ៉ូ រីករាយណាស់ដោយបានមកដល់កន្លែងសម្រាកសារជាថ្មី ។


សូបិន ល សំពត់អាវនៅហាងប៉ារ៉ាឌី

ស្អែកឡើង សូបិនត្រូវទៅលសំពត់អាវខ្មែរ ដែលបានបញ្ជាកាត់ដេរពេលមុនចេញទៅកែប តែមុននឹងទៅ វិរចិត្ត បានបបួលទៅហូបគុយទាវសាច់ជញ្រ្ជាំនៅផ្លូវប៉ាស្ទ័រ ដ៏មានប្រជាប្រិយមួយនៅភ្នំពេញដែលឮល្បីថា ធ្វើគុយទាវឆ្ងាញ់ជាច្រើនឆ្នាំមកហើយ ។ មែន! ភ្ញៀវចូលប្អូនសារក្នុងមួយថ្ងៃក្នុងអាគារដ៏អ៊ូអរនោះ មកហូបគុយទាវដែលមានសាច់ជ្រូកជញ្រ្ជាំ រុយមកទំមាត់ចានខ្ញុំក៏លែងសួរខានដូចមុនហើយ បក់ចេញទៅជាការស្រេច ប៉ុន្តែសម្រាមក្រដាស់ជូតមាត់ផ្តើមគរនៅក្រោមតុដោយភ្ញៀវចូលចិត្តចោលសម្រាមខ្លួនរបៀបនេះហើយអ្នកបំរើទៀតសោតក៏ជូតតុទម្លាក់សម្រាមទៅដីដែរ ធ្វើឱ្យដីក្លាយជាធុងសម្រាមដ៏ធំមួយដែលគេដើរជាន់ពព្លាចតែគ្មាននរណាចាប់អារម្មណ៍ឡើយ ។ វីរចិត្រ និយាយថា កាលខ្លួននៅពីក្មេងធ្លាប់មកបំរើតុគុយទាវនៅទីនេះ ដើម្បីយកលុយទៅរៀន ហើយស្គាល់ម្ចាស់ហាងយ៉ាងជិតស្និត គេមានទម្លាប់មួយ គឺមិនបោសសំអាតមុនចប់ភ្ញៀវនាវេននិមួយៗទេ ព្រោះភ្ញៀវមានអារម្មណ៍ថា តែហាងស្អាតពេកច្រើនតែលក់របស់ថ្លៃ ម្លោះហើយភ្ញៀវដូចយើងទ្រាំស្ទើរមិនបានជាពិសេស ប៊ុណ្ណារ៉ូ នឹងម្តាយរបស់គេដែលរអ៊ូមិនឈប់ ព្រោះតែខំទ្រាំនេះ ។

ចេញពីហាងគុយទាវដែលយើងនាំគ្នាបរិយាយកំប្លែងសើចមិនចេះចប់យើងក៏ទៅដល់កន្លែងកាត់សំពត់អាវប្រណិតខ្មែរឈ្មោះ "ប៉ារ៉ាឌី" នៅទួលទំពូងដែលជាហាងដ៏ល្បីឈ្មោះជាងគេមួយនៅទីក្រុងភ្នំពេញខាងសម្លៀកបំពាក់ខ្មែរ យើងបានឃើញស្នាដៃប្រណិតរហ័សទាន់ចិត្តនឹងផ្សព្វផ្សាយទូលំទូលាយដោយរូបថតគំរូសំលៀកបំពាក់ក្នុង "កាតាឡុក" ចំរុះពណ៌ក្រាសឃ្មឹកជ្រើសយកមួយណាក៏ល្អដូចគ្នា ។ អ្នកស្រីវណ្ណាតជាម្ចាស់ហាង បាននាំយើង ឱ្យទៅឃើញរោងជាងនៅពីល្វែងក្រោយផ្ទះបង្ហាញពីម៉ាស៊ីនច្រើនសិបគ្រឿងបញ្ជាដោយស្ត្រីជាងដេរ ប្រមាណ១០០នាក់ ដែលចេះដេរក្រណាត់ប៉ាក់ ក្រណាត់សូត្រផាមួង ហូល...។ល។ មានយុវនារីរាប់សិបនាក់ទៀត កំពុងតែប៉ាក់ ឌិន លើក្រណាត់រាប់ផ្ទាំងធ្វើដោយដៃ អង្គុយប៉ាក់តាំងពីក្រោយដល់មុខនឹងក្នុងហាងផង សម្រាប់បំរើអតិថិជនដ៏ច្រើនហើយកើនរាល់ថ្ងៃផង ។ សូបិនរីករាយនឹងសំពត់អាវមួយ "កំប្លែ" ដែលលនាថ្ងៃនេះណាស់ ស្បែកទៅសមនឹងដងខ្លួនតែម្តង ហើយមួយគ្រឿងនេះនឹងក្លាយជាសំលៀកបំពាក់ចូលគាល់ហ្លួង នាថ្ងៃស្អែកជាប្រាកដ ។

នាវេលាល្ងាចនៃថ្ងៃ២៣ដដែលនោះ ក្រុមអ្នកដំណើរទាំងអស់បានមកជួបជុំគ្នានៅហាងកាហ្វេទំនើបមួយស្ថិតនៅក្បែរវិមានឯករាជ្យ ដើម្បីទទួលព័ត៌មានណែនាំពីម្ចាស់ក្សត្រី ស៊ីរិយ៉ា ស៊ីសុវត្ថិ ដែលជាអ្នករៀបពីកម្មវិធីទាំងមូលលំអិតក្នុងនាមជារដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំងផង **តទៅទំព័រទី ០៨**



តមកពីទំព័រទី ០៧

## ដំណើរពីអាមេរិកទៅអាស៊ី...

នឹងជាម្តាយសាមីខ្លួនកូនស្រីផង ដើម្បីចូលថ្វាយបង្គំគាល់ហ្លួង នាវេលាថ្ងៃស្អែកវេលាម៉ោង ១១ព្រឹក។

ថ្ងៃទី២៤តុលា ជាថ្ងៃ"ឌីដេយ"(D day) គឺជាថ្ងៃដែលជាបុព្វហេតុចំបងនៃដំណើរទៅអាស៊ីរបស់យើង...។ កូនកម្លោះកូនក្រមុំនឹងអ្នកកំដរ ៦រូប ត្រូវទៅចំតែងខ្លួន តាំងពីម៉ោង៤ភ្លឺ មានតាំង



គ្រួសារបង្កើតរបស់ និរតី [illegible] ថតរូបជាមួយព្រះមហាក្សត្រ

ពីធ្វើសក់ ធ្វើមុខ តែងសំពត់អាវគ្រឿង សមដំណើររបៀបថ្វាយបង្គំហ្លួងសីហមុនី ចំណែកឯអ្នកនៅសល់មានម្តាយឪពុកខាងកូនប្រុសជាវរសេនីយត្រី បារាំងខាង"ប៉េអឹម" ឬប៉ូលីសយោធាមានខ្លួនខ្ញុំនឹងសូបិនជាឪពុកខាងស្រី(ប៉ុណ្ណារ៉ូមិនបានចូលរួមទេ ដោយហេតុនៅក្មេងពេកពុំអាចរក្សាសណ្តាប់ធ្នាប់នៅមុខព្រះភក្ត្រស្តេចផែនដីបាន) មានកូន១នៃសាមីខ្លួនមានក្រុមគ្រួសារនឹងមិត្តជិតស្និតត្រូវមកដល់មុខវាំងនៅម៉ោង១០។ វេលាម៉ោង ១០ព្រឹកគត់ រថយន្ត"វ៉ែន"២គ្រឿង ដឹកមុខដោយម៉ូតូពីធីការព្រះបរមរាជវាំងនៃកងរក្សាព្រះអង្គបាននាំយើងចូលទៅដល់ជើងជណ្តើរព្រះរាជដំណាក់"ខេមរិន្ទ" ។ នៅទីនោះកងយោធារក្សា



គូស្វាមីភរិយា និងក្រុមគ្រួសារសំណេះសំណាងជាមួយព្រះមហាក្សត្រ

ព្រះអង្គ២-៣រូប មានអ្នកយកព័ត៌មានទូរទស្សន៍កម្ពុជានឹងមន្ត្រីវាំងបានបង្ហាញខ្លួនទទួលគួរសមរួចឱ្យយើងចាំរហូតដល់ម៉ោង១១ខ្វះ៥នាទី ទើបនាំដំណើរជា២ជួរប្រកបដោយសណ្តាប់ធ្នាប់ឡើងកាំជណ្តើរដ៏ធំដ៏គួរឱ្យស្ញប់ស្ញែងទៅរកទ្វារមុខនៃព្រះរាជដំណាក់នាំមុខដោយម្ចាស់ក្សត្រីយជាម្តាយនឹងម្តាយមីងព្រះនាមសម្តេចឡូឡុត... នៅមាត់ទ្វារធំនោះ ព្រះមហាក្សត្រនរោត្តម សីហមុនី គង់រង់ចាំទទួលភ្ញៀវរួចជាស្រេចធ្វើឱ្យបរិយាកាសមានភាពរំភើបក្រៃលែងនៅពេលចូលកាន់តែជិតដល់ជួបព្រះភ័ក្ត្រមនុស្សដែលសំខាន់ផុតគេនៅប្រទេសកម្ពុជានេះ។ ព្រះអង្គទទួលគួរសមនឹងភ្ញៀវហើយឱ្យនាយកពិធីការនាំភ្ញៀវចូលក្នុងប្រាសាទ"ខេមរិន្ទ"ទាំង២ជួរ ដែលខាងឆ្វេងជាជួរគ្រួសារខាងប្រុស រីឯខាងស្តាំជាជួរខាងស្រី ។ មុននឹងគង់ប្រថាប់នៅកៅអីសាឡុងព្រះមហាក្សត្រទទួលការក្រាបថ្វាយបង្គំពីភ្ញៀវម្នាក់ម្តងឱបថើបតាមរបៀបបារាំងដល់គូរស្វាមីភរិយាដែលព្រះអង្គធ្លាប់ស្គាល់កូនស្រីតាំងតែពីព្រះអង្គគង់នៅក្រុងប៉ារីសប្រទេសបារាំង ជាឯកអគ្គរាជទូតប្រចាំយូណេស្កូ មកម្លេះនឹងរលាក់ដៃភ្ញៀវប្រុសទាំងអស់ រួចមកក៏ធ្វើពិធីប្រោះព្រំប្រទានទឹកពរជ័យដល់កូនក្មួយដែលទើបរៀបការ ។ ព្រះអង្គបានសំណេះសំណាលយ៉ាងរួសរាយជាភាសាបារាំងជាមួយភ្ញៀវបារាំង(ដែលស្ទើរតែទាំងអស់ចេះភាសាបារាំងលើកលែងតែសូបិនចេញ) នឹងជាភាសាខ្មែរជាមួយខ្មែរ (ដែលសូបិនស្តាប់យល់តែភាគ

តទៅលេខក្រោយ

MIDDLESEX
Community College



Everyone teaches, everyone learns.

Middlesex offers 70+ degree & certificate programs, and hundreds of noncredit courses. Earn a degree, begin a bachelor's degree or upgrade your skills.

- A price you can afford
- Small-class environment
- Flexible schedule
- Online or on campus

Classes begin
JANUARY 20
REGISTER NOW!

STAY CONNECTED...

To learn more, call 1-800-818-3434 or visit www.middlesex.mass.edu

# ឆ្នាំថ្មី , រដ្ឋ រ៉ូដអាយឡិនបញ្ចុះថ្លៃបង់ពន្ធ

**ដកស្រង់ពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិដោយ : ថាច់ វណ្ណា**



ចាប់ផ្តើមពីថ្ងៃព្រហស្បតិ៍ទី១ មករា ឆ្នាំ២០១៥ ផ្នែកពន្ធដារដ្ឋរ៉ូដអាយឡិនបានបញ្ចុះថ្លៃពន្ធក្នុងតំបន់នីវអ៊ីងឡិន (New England) ទាបជាងតំបន់ផ្សេងទៀតក្នុងរដ្ឋ , តម្លើងប្រាក់ខែពី៨ដុល្លារទៅ៩ដុល្លារក្នុង១ម៉ោង.ទន្ទឹមនឹងនេះមានការផ្តើមឡើងនូវគម្រោងច្បាប់១សំរាប់តម្លើងប្រាក់ខែក្នុងរយៈពេល៣ឆ្នាំខាងមុខ នឹងឡើងទៅដល់១០ដុល្លារក្នុង១ម៉ោង ច្បាប់នេះនឹងត្រូវបានគេយកមកធ្វើសេចក្តីសម្រេចក្នុងសមាជសភានាថ្ងៃទី៦ មករា នេះ ។

-តាមធម្មតាកម្មករធ្វើការ៤០ម៉ោងក្នុង១សប្តាហ៍ ថ្លៃក្នុង១ម៉ោង៨ដុល្លារ គិតជាប្រាក់ចំណូលបាន១៦.៦៤០ដុល្លារក្នុង១ឆ្នាំ ។

-ឆ្នាំថ្មី ៩ដុល្លារក្នុង១ម៉ោង គិតប្រាក់ចំណូលបាន១៨.៧២០ដុល្លារក្នុងឆ្នាំ ។

ត្រង់ចំណុចសំខាន់ដែលលោកអភិបាលរដ្ឋ ឆែហ្វី បានចុះហត្ថលេខាលើច្បាប់ប្រាក់ខែកាលពីរដូវក្តៅកន្លងមក ជាសញ្ញាដើម្បីដឹកនាំសភាឱ្យធ្វើការធានានិងខំប្រឹងប្រែងជួយដល់អ្នកដែលមានបៀរវត្សរ៍ទាបបំផុត ឱ្យពួកគេអាចមានលទ្ធភាពចិញ្ចឹមខ្លួន និងគ្រួសាររបស់ខ្លួនក្នុងរដ្ឋរ៉ូដអាយឡិនដែលមានតម្លៃខ្ពស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

-ក្នុងរដ្ឋម៉ាសាឈូសេតវិញ ទើបនឹងបានធ្វើការសម្រេចលើច្បាប់ថ្មី១ ដោយតម្លើងប្រាក់ខែពី៨ទៅ១១ដុល្លារ ជារៀងរាល់ដើមឆ្នាំ១មករា និងតម្លើង១ដុល្លាររហូតដល់ឆ្នាំ២០១៧ ។

ក្នុងឆ្នាំថ្មី ២០១៥ នេះរដ្ឋរ៉ូដអាយឡិន និងរដ្ឋម៉ាសាឈូសេតមានតម្លើងប្រាក់ខែក្នុង១ម៉ោង៩ដុល្លារស្មើគ្នា ។

រីឯរដ្ឋ ខិនណែកធីខាត់ (Connecticet) វិញកំពុងតម្លើងប្រាក់ខែឱ្យបាន១០.១០ដុល្លារក្នុងឆ្នាំ២០១៧ ។

ដំណឹងល្អ ឬអាក្រក់សំរាប់អ្នកបង់ពន្ធយោងទៅតាមតំបន់សេដ្ឋកិច្ចរបស់វិសាលគម ឬយោងទៅតាមវិសាលភាពសេដ្ឋកិច្ចក្នុងតំបន់ ។ ឧទាហរណ៍ : ក្នុងតំបន់នីវអ៊ីងឡិន (New England) បញ្ចុះថ្លៃបង់ពន្ធពី៩%ទៅ៧% នោះជាតម្លៃទាបបំផុតក្នុងតំបន់ ។

សព្វថ្ងៃនេះរដ្ឋរ៉ូដអាយឡិនត្រូវបង់ប្រាក់ជំនឿ (Credit) ឱ្យសហព័ន្ធរដ្ឋ២៥%ច្បាប់ថ្មីឆ្នាំថ្មីត្រូវបង់តែ១០%ប៉ុណ្ណោះ ថែមទាំងបានសងមកវិញ ក្នុងបំណាច់ឆ្នាំ១០០%ទៀតផង ។

ប្រសើរជាងច្បាប់ចាស់ក្នុងពេលបំណាច់ឆ្នាំសងបានតែ៥០%ប៉ុណ្ណោះ ។

ប្រជារាស្ត្រក្នុងរដ្ឋរ៉ូដអាយឡិន និងបានសងថ្លៃពន្ធ១០០% ចំពោះអ្នកដែលមានប្រាក់ចំណូលទាប ៕

តមកពីទំព័រទី ០៤ បទសម្ភាសន៍..

**ខ្មែរផុស ស.រ.អា.** មានគេមកប្រាប់ហើយឬនៅ?

**វ៉ាឌី ម៉ម:** ទេ តែខ្ញុំបានឮ! ខ្ញុំដឹងតួនាទីខ្ញុំច្បាស់ថាខ្ញុំជាបុគ្គល វ៉ាឌី ម៉ម ឥតមាននរណាមកប្រាប់ឆ្ងល់ស្មាំអីទេ!

**ខ្មែរផុស ស.រ.អា.** នៅថ្ងៃ០៧មករា ២០១៥នេះ លោកនឹងទៅធ្វើសច្ចាប្រណិធានចូលកាន់មុខដំណែង នឹងប្រារព្ធពិធីជប់លៀងពីជ័យជំនះលោកនាថ្ងៃដដែលនោះ ប្រជាជនខ្មែរច្រើនយកទំនាស់នយោបាយកម្ពុជាមកជាទំនាស់សង្គមឡូវែល ដោយថ្ងៃ ០៧មករា ជាថ្ងៃជ័យជំនះគណបក្សប្រជាជនដែរនោះ តើលោកមានយោបល់យ៉ាងណាដែរពីរឿងនេះ?

**វ៉ាឌី ម៉ម:** អីចឹងហើយបានជាថា សង្គមយើងមានការខ្វះខាតច្រើន ជាពិសេសការយល់ដឹងតែម្តង ដូចជារឿងខ្ញុំអីចឹងបានឮអ្វីមួយវាយតម្លៃតៗគ្នា អីចឹងហើយខ្ញុំថា បើឮរឿងអ្វីមិនស្រួលអាចសួរមកខ្ញុំភ្លាមទ្វារខ្ញុំចំហជានិច្ច...ខ្ញុំធ្វើសច្ចាប្រណិធានថ្ងៃ ០៧មករា មែន ធ្វើពិធីជប់លៀងនៅល្ងាចថ្ងៃដដែលពីម៉ោង ៥កន្លះ ដល់ ៧កន្លះ នៅ:

Mt. Pleasant Golf Club

141 Staples Street Lowell, Mass 01851

ឥតមានទាក់ទងអ្វីនឹងគណបក្សប្រជាជនទេ ។

**ខ្មែរផុស ស.រ.អា.** សូមអរគុណនឹងសូមជូនពរ រីករាយជាមួយគ្រួសារ នាឱកាសចូលឆ្នាំថ្មីនេះ ៕






## តមកពីទំព័រទី ០៤ អាចស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន...

សារជាចុងក្រោយបំផុតមួយ ដើម្បីជូនទៅដល់មនុស្សជាទីស្រលាញ់របស់នាង។

យោងតាមប្រភពព័តិមានបានឱ្យដឹងថា នារីអាកាសចរណ៍ម្នាក់នោះឈ្មោះ Kahairunnisa Haidar Fauzi អាយុ២២ឆ្នាំ បានសរសេរសារដ៏ខ្លីមួយនៅលើកន្ទ្បេងដៃដែលមានន័យថា "ខ្ញុំស្រឡាញ់អ្នកផ្ញើរមកពីរយ:កម្ពស់38,000ហ្វីត" **តទៅទំព័រទី ២០**



## តមកពីទំព័រទី ០១ ទ្រង់រណឫទ្ធិ : ទៅហើយមកហ៊្វុនស៊ិនប៉ិចវិញ

ចូលរួមសម្ពោធទីស្នាក់ការបក្សសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤ ព្រះអង្គនឹងកែប្រែគម្រោងសមាជគណបក្សសង្គមរាស្ត្ររាជាធិបតេយ្យរបស់ទ្រង់នៅថ្ងៃទី១៩ មករាខាងមុខទៅជាសមាជគណបក្សហ៊្វុនស៊ិនប៉ិចវិញ។

ទ្រង់មានបន្ទូលបញ្ជាក់ទៀតថា គណបក្សហ៊្វុនស៊ិនប៉ិចមិនមានបំណងធ្វើនយោបាយប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា ឬគណបក្សណាមួយផ្សេងនោះទេ ប៉ុន្តែក៏មិនមែនជាកូនជឹងរបស់គណបក្សណាមួយនោះដែរ។

ចំណែកអគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច លោក ញឹក ប៊ុនឆៃ ជាអតីតដៃគូជម្លោះជាមួយសម្តេចក្រុមព្រះដែលនាំឱ្យបែកបាក់គណបក្សនេះធ្ងន់ធ្ងរនោះ បានថ្លែងសារទរចំពោះការវិលមកទ្រនំចាស់វិញនេះ។ លោកបន្តថា ដោយមើលឃើញគ្រប់គ្នានូវលទ្ធផលនៃការបាក់កន្លងមកលោកសទ្ធាថា នឹងមិនឱ្យមានការបែកបាក់ជាថ្មីទៀតឡើយទោះមានរឿងអ្វីកើតក៏ដោយចុះ។

កាលពីថ្ងៃ១៨ តុលា ឆ្នាំ២០០៦ គណបក្សហ៊្វុនស៊ិនប៉ិចដែលដឹកនាំដោយលោក ញឹក ប៊ុនឆៃ ធ្លាប់ធ្វើសមាជបណ្តេញសម្តេចក្រុមព្រះចេញពីគណបក្សនេះ ដោយមានជម្លោះផ្ទៃក្នុងធ្ងន់ធ្ងរមិនអាចដោះស្រាយបាន។

សម្តេចក្រុមព្រះបានបង្កើតគណបក្សថ្មីមួយទៀត ឈ្មោះថាគណបក្សសង្គមរាស្ត្ររាជាធិបតេយ្យ។ បក្សថ្មីនេះមិនទាន់ធ្វើសមាជផងក៏គ្រោងរំលាយចោលវិញ ដោយសារព្រះអង្គយាងទៅគណបក្សចាស់វិញ គឺគណបក្សហ៊្វុនស៊ិនប៉ិចដែលគ្រោងធ្វើសមាជបោះឆ្នោតប្រធានថ្មីនៅថ្ងៃទី១៩ មករាខាងមុខនេះ ជំនួសសម្តេចរាជបុត្រី ព្រះអនុជនរោត្តម អរុណរស្មី ដែលជាប្រធានគណបក្សបច្ចុប្បន្ននេះ។

សម្តេចក្រមព្រះនរោត្តម រណឫទ្ធិ នៅក្នុងថ្ងៃចំរើនព្រះជន្មគម្រប់ខួប៧១ព្រះវស្សានៅថ្ងៃសុក្រទី០២ មករា ទ្រង់ រណឫទ្ធិ សម្តែងព្រះទ័យរីករាយចំពោះការយាងវិលត្រឡប់ទៅគណបក្សដែលកូនចៅធ្លាប់បណ្តេញទ្រង់ចេញកាលពីប្រមាណជា៩ឆ្នាំមុននេះ។ ព្រះអង្គបញ្ជាក់ថា ការវិលទៅគ្រប់គ្រងពេលនេះ គឺដើម្បីបង្រួមបង្រួមក្រុមរាជានិយមឡើងវិញ ដើម្បីចូលរួមកសាងជាតិ និងដោះស្រាយបញ្ហាផ្សេងៗដែលកំពុងកើតមានក្នុងសង្គមបច្ចុប្បន្ន គឺមិនមែនតាមការរៀបចំណាមួយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដូចការចោទប្រកាន់ឡើយ៕

**ដកស្រង់ដោយខ្មែរប៉ុសស.រ.អា.**

GREATER LOWELL
CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

**A resource for your business or organization!**
**សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក**

Networking Events — ព្រឹត្តិការណ៍ទំនាក់ទំនង
Seminars — សន្និសីទ
Resources — រកធនធាន
TV & Radio Shows — កម្មវិធីទូរទស្សន៍ និងវិទ្យុ
And more! — និងនៅមានច្រើនទៀត



តមកពីទំព័រទី ០១

## ទៅលេងគ្រួសារនៅស្រុកបាយឆៅ...

តំបន់ជារមនីយដ្ឋានវប្បធម៌ភូមិកំណើតរបស់គេតាំងពីជំនាន់ស្ដេច"ជ័យជេដ្ឋាទី២"មកណាស់ដែរ។

ខ្ញុំ សូបិន ដែលជាអ្នកនាំដំណើរធ្លាប់ចងចាំពីឪពុករបស់ខ្ញុំនិយាយពីតំបន់ "សាយគួន" នេះថា **១**-នៅតាមដងទន្លេមេគង្គរហូតដល់ចុងខាងត្បូងជាតំបន់អតីតកម្ពុជាមានខេត្តខ្មែរចំនួន២៤ មានខ្មែរច្រើនរស់នៅជាជនជាតិភាគតិច ២-នៅតំបន់កណ្ដាលចន្លោះពី"សាយគួន"ទៅ "ហាណូយ" ដែលនៅតំបន់កណ្ដាលជាអតីត"ចម្ប៉ា"សម្បូរចាមចារ៉ៃ អំបូរភ្នំ នឹងលាយឡំនឹងយួនខ្លះៗ ៣-គឺនៅជុំវិញ"ហាណូយ"រហូតទៅខាងជើងជាប់នឹងចិនទើបជាតំបន់ឫសគល់យួនសម្បូរយួនរស់នៅច្រើន។

ត្រឡប់មកនិយាយពីសាយគួនវិញ ខ្ញុំបន្តនាំម្ដាយ ក្មួយ បង នឹង មីង ទៅកំសាន្តនៅកន្លែងល្អៗ ស្រស់ស្អាត របស់ទីក្រុងយួនខាងត្បូង



ឧទ្យានផ្កាឈូក

ដូចជានៅរាត្រីដំបូងទៅជួលបន្ទប់២ នាសណ្ឋាគារ "ខាយហ្វួង" ដែលមានលំដាប់ថ្នាក់ផ្កាយ៤កន្លះ ដោយសារសណ្ឋាគារនោះស្ថិតនៅមិនឆ្ងាយពីឧទ្យានដ៏ធំបង្អស់មួយឈ្មោះ"ដាំសែង"ដែលគេនឹងនាំគ្នាទៅកំសាន្តនៅថ្ងៃស្អែក។ បន្ទប់១នៅជាន់ទី៣ នឹងមួយទៀតនៅជាន់ទី១៦ នៃសណ្ឋាគារ ៣០ជាន់ដែលទើបនឹងសង់ហើយកាលពី២ឆ្នាំមុន។ ពីបន្ទប់ជាន់ខ្ពស់នោះ ម៉ែខ្ញុំនឹងបងប្អូនមិនហ៊ានមើលមកក្រោមទេ វាធ្វើឱ្យវិលមុខពីព្រោះនេះជាលើកដំបូងបង្អស់សម្រាប់ពួកគេដែលបានភ្លក់រស់ជាតិអាគារខ្ពស់កប់ពពក ហើយទទួលពួកគេជាភ្ញៀវជាន់ខ្ពស់របៀបនេះ។ ក្នុងបន្ទប់និមួយៗមានចែកជាបន្ទប់ដេកតូចៗ២ នឹងបន្ទប់ទទួលភ្ញៀវមួយទៀត ដែលម្ខាងៗអាចផ្ទុកអ្នកដំណើរយើងបាន៦-៧នាក់ បានយ៉ាងងាយស្រួលក្នុងតម្លៃប្រមាណ៤០ដុល្លាមួយបន្ទប់ក្នុង១យប់តែប៉ុណ្ណោះ។ បុគ្គលិកសណ្ឋាគារបានដកយកឯកសារសំគាល់ខ្លួនយើងទុកមានទាំងលិខិតឆ្លងដែនផងខ្ញុំនឹងកូនផង រហូតដល់ចេញទៅ ទើបប្រគល់ឱ្យវិញ។ នៅសល់ពេលល្ងាចយើងដើរតាមហាងទៅរកទិញឥវ៉ាន់ទុកឱ្យបងប្អូនប្រើប្រាស់ចូលហាងជាច្រើនរកអ្វីក៏មិនបានចុងបញ្ចប់ទៅដល់ហាងមួយដ៏ធំឈ្មោះ"ប៊ិនថាន់"គឺជាហាងដែលរដ្ឋអំណាចជាម្ចាស់។ ម៉ោង៦ល្ងាចទៅហើយហាងគេជិតបិទនៅទីនោះ យើងមិនចាំបាច់តថ្លៃដូចកន្លែងឯទៀតទេ តែមានរបស់ល្អតម្លៃថោកគួរសមដែលខ្ញុំអាចទិញសំពត់អាវឱ្យម៉ែមួយ"កំប្លេ"យ៉ាងសមរមនឹងឆាប់រហ័ស ហើយឃើញទឹកមុខគាត់ហាក់សប្បាយចិត្តណាស់ដោយភាពក្រីក្រខានទិញសំលៀកបំពាក់ច្រើនខែណាស់ហើយរីឯបងប្អូនឯទៀតៗបានទិញរបស់ឱ្យម្នាក់មួយរួចហើយពេលមុនចេញពីបាយឆៅមក។

ស្អែកឡើងយើងចេញដំណើរទៅទិញសំបុត្រចូលកំសាន្តពេញមួយថ្ងៃ នៅសួនឧទ្យានដ៏ធំបំផុតនៃ"សាយគួន"ដែលមានឈ្មោះថា"ដាំសែង"ទៀត។ នៅក្នុងនោះមានល្បែងកំសាន្តសម្រាប់ក្មេងចាស់គ្រប់អាយុមានអាងហែលទឹក អាងជិះទូកក្ដាន មានភោជនីយដ្ឋាន មានរោងល្ខោន នឹងកន្លែងកំសាន្តច្រើនទៀត។ យើងអាចចូលទៅកន្លែងកំសាន្តនិមួយៗបានដោយពុំចាំបាច់បង់លុយផ្សេងទៀតទេ ពីព្រោះសំបុត្រចូល១០ដុល្លាម្នាក់ទៅហើយផ្ដល់សិទ្ធឱ្យកំសាន្តគ្រប់កន្លែងបានដែលបងប្អូនខ្ញុំឆ្លៀតយកឱកាសនេះ ទៅកំសាន្តពីកន្លែងមួយទៅកន្លែងមួយយ៉ាងចាស់ដៃតែម្ដងរីឯចាស់ៗវិញ ពួកគាត់ចេះតែរកកន្លែងអង្គុយសម្រាក ពីព្រោះឧទ្យាន"ដាំសែង"នោះធំពេក។

លេងពីព្រឹកទល់រសៀលចប់យើងនាំគ្នាចេញពីសួន"ដាំសែង"ឬឧទ្យាន"ផ្កាឈូក"ទៅហូបបាយជុំគ្នានៅកន្លែងដ៏ប្រណិតមួយខ្ញុំគិតថានេះជា"កាដូ"ដល់ក្រុមគ្រួសារជាចុងក្រោយ ពីព្រោះចំណាយទិញទឹកចិត្តក្រុមគ្រួសារជាទីស្រឡាញ់នឹងនឹករលឹកច្រើនណាស់ហើយមុននឹងខ្ញុំឡើងយន្តហោះនាថ្ងៃស្អែកវេលាម៉ោង១១ព្រឹកចេញដំណើរទៅចាំប្ដីត្រឡប់ពីភ្នំពេញមកជួបគ្នានៅហុងកុងសម្រាកទីនោះ៣ថ្ងៃក្នុងផ្លូវត្រឡប់មក"បូស្តុន"នៃសហរដ្ឋអាមេរិកវិញ ក៏ប៉ុន្តែម៉ែមិនព្រមឱ្យចំណាយប្រាក់ច្រើន ក៏បញ្ជាឱ្យអ្នកបើក



ឡានទៅរកអាហារឋានកន្លែងសមរមថោកល្មមវិញ បានដូចចិត្តតែនៅកន្លែងនោះភ្ញៀវច្រើនចូលមិនដាច់អ្នកបំរើធ្វើការលឿនហើយឆ្លាតប៉ុនប្រសព្វ ក្រោយមកទើបខ្ញុំដឹងថា ពួកនោះសុទ្ធតែជាកូនខ្មែរទាំងអស់ ។

នៅរាត្រីចុងបញ្ចប់នៃដំណើរមក "បាយឆៅ"១២ថ្ងៃរបស់ខ្ញុំបានបណ្ដុះឡើងវិញនូវ



អនុស្សាវរីយ៍បន្តផ្ងាប់ទៅអតីតកាល កាលពី១៥ឆ្នាំមុនកែរតម្រូវភាពស្រពិចស្រពិលក្នុងព្យុះជីវិតប្រកបដោយឧបសគ្គថ្មីៗនៃការកសាងជីវិតខ្ញុំនៅតាមផ្លូវនៃដែនដីថ្មីបែកឆ្ងាយពីសំបុកគ្រួសារ ដោយបានត្រឡប់ទៅរកជួបមនុស្សដែលជាអ្នកធ្លាប់សង្គ្រោះកុមារីម្នាក់នៅស្រុកយួន កាលពីច្រើនឆ្នាំមកហើយនោះ តែគេមិនបានបំភ្លេចចោលនៅឡើយ ដោយគេបានចងចាំថា ឪពុកនាងនោះ



បានតស៊ូ រហូតដល់យកនាងទៅស្រុកអាមេរិកបាន ហើយក៏បាត់ដំណឹងសូន្យឈឹងរហូតដល់ថ្ងៃនេះ។ ជាមួយនឹងម៉ែខ្ញុំថែសម្បូរបងស្រីខ្ញុំបងលាងបងប្រុសខ្ញុំនឹងម្ដាយមីង បង្កើត ខ្ញុំយើងបានបានជជែកប្រាជ្ញព្រោកនៅក្នុង បន្ទប់ដេកជាន់ទី១៦ដោយ គ្មានងោកងុយនិយាយពីភាពរីករាយនៃការជួប ជុំគ្នាជាថ្មីពីប្អូនពីរនាក់ទៀត ដែលមិនបានមក លេងជាមួយគ្នានៅឡើយ ហើយក៏ស្រងូតស្រងាត់នឹកទៅដល់ការបែកគ្នាទៅវិញ នាថ្ងៃនេះ ពីព្រោះម៉ោង៣ទៀបភ្លឺទៅហើយ រីឯក្មួយៗ ដូចជាអាឡៃ អាម៉ៃ អ៊ិនទ្រី... បានដេកលក់ស្កប់ស្កល់យូរបន្តិចទៅហើយ ។

ម៉ោង៩ព្រឹកយើងមកដល់អាកាសយានដ្ឋាន "តាន់ស៊ិនញ៉ឹក" លាម៉ែ លាបងៗ មីងនឹងក្មួយៗខ្ញុំប្រកបដោយលំបាកក្នុងចិត្តយ៉ាងជ្រាលជ្រៅទប់ទឹកភ្នែកមិនបានគ្រប់គ្នា ប៉ុន្តែលើកនេះមិនដូចលើកមុនទេ យើងក្រៀមក្រំក្នុងចិត្តមែនតែមានសង្ឃឹមជាក់ច្បាស់នឹងមានទាំងគម្រោងបន្តជីវភាពភ្លឺស្វាងជាងមុនទៀតផង។ រីឯ ប៊ុណ្ណារ៉ូ ថ្វីត្បិតតែមិនទាន់ដឹងអីលេងច្រើនតែមិនចង់បែកពីបងប្អូនដែលទើបនឹងបានជួបគ្នាជាលើកដំបូងនោះទេ ពិសេសទៅទៀតនោះ គេបានប្ដើមនិយាយភាសាខ្មែរយ៉ាងច្បាស់លាស់មានប្រយោគស្រួលយល់ តែនិយាយរដឺនបែបខ្មែរកម្ពុជាក្រោមងាយស្រួលទាក់ទងនឹងក្រុមគ្រួសារដែលនិយាយភាសាខ្មែរទាំងអស់គ្នាទៀតផង។ ម៉ោង១១តត់យន្តហោះបានចេញផុតទៅ ហើយខ្ញុំនឹកដល់ក្រុមគ្រួសារដែលកំពុងជិះឡានវែនត្រឡប់ទៅដល់ បាយឆៅ នៅ៥ម៉ោងទៀត ខ្ញុំនឹង ប៊ុណ្ណារ៉ូ នឹងទៅដល់ហុងកុងនៅ២ម៉ោងទៀត ពេលយន្តហោះឡើងដល់ពពក ប៊ុណ្ណារ៉ូ ផ្ដើមយំ ហើយងាកមកសួរខ្ញុំថា "បងៗទៅណាបាត់មេចក៏មិនឃើញ?" ខ្ញុំដឹងថា គេមិនចង់មានការបែកគ្នាទៀតទេ តែយើងបានផ្ដើមទៅទស្សនាដែនដីនៃប្រទេសចិនថ្មីមួយផ្នែកទៀត ដែលយើងពុំដែលស្គាល់ទៅហើយ ៕

**(ចប់បរិបូរណ៍)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាញខាងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី៣១ ខែធ្នូ ឆ្នាំ២០១៤

# ជំនួយការរបស់លោក កឹម សុខា ចោទប្រកាន់ថា មានការប្រព្រឹត្តអំពើពុករលួយនៅក្នុងគណបក្សសង្គ្រោះជាតិ

**ដោយ ម៉ិច ដារ៉ា AND អេឡិក វ៉ៃម៉ឺម៉ីនស៍** | **DECEMBER 29, 2014**

ជំនួយការម្នាក់ក្នុងចំណោមជំនួយការផ្ទាល់របស់លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិប្រឈមនឹងវិធានការវិន័យពីគណបក្សប្រឆាំងមួយនេះ បន្ទាប់ពីជំនួយការរូបនេះបានចោទប្រកាន់លោក កឹម សុខា កាលពីថ្ងៃសៅរ៍ថា បានរិះគន់លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិថាមានជាប់ពាក់ព័ន្ធនៅក្នុងអំពើពុករលួយ។

ថ្លែងនៅក្នុងកិច្ចប្រជុំជាលើកដំបូងរបស់បណ្តាញសង្គម "ខ្មែរដើម្បីខ្មែរ" ដែលដឹកនាំដោយលោក កែម ឡី អ្នកវិភាគនយោបាយឯករាជ្យ លោកស្រី លក្ខណ៍ សុភាព ដែលបានចោទប្រកាន់គ្នាជាសាធារណៈជាមួយលោក កឹម សុខា កាលពីខែមុនបានលើកឡើងថា លោក កឹម សុខា បានធ្វើការរិះគន់ដូច្នេះអំឡុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សមួយដែលធ្វើឡើងនៅដើមខែនេះ។

លោកស្រីបានមានប្រសាសន៍ថា "កាលពីថ្ងៃទី៥ ខែធ្នូ" លោក កឹម សុខា បានរិះគន់ថា ក្នុងទឹកប្រាក់ចាប់ពីប្រហែល៣០ ឬ៤០លានដុល្លារ លោក សម រង្ស៊ី បានយកអស់២០លានដុល្លារទៅហើយ។ ខ្ញុំមិនអាចចូលរួមនៅក្នុងសង្គមមួយដែលមានមេដឹកនាំប្រព្រឹត្តអំពើពុករលួយបានឡើយ"។

លោកស្រី សុភាព ដែលបានចូលរួមពាក់ព័ន្ធនៅក្នុងចលនាប្រឆាំងក្នុងប្រទេសកម្ពុជាចាប់តាំងពីលោក សម រង្ស៊ី បានបង្កើតគណបក្សជាតិខ្មែរកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៥មក មិនបានរៀបរាប់អំពីការអះអាងរបស់លោកស្រីទេ ប៉ុន្តែបានលើកសរសើរលោក កែម ឡី ជាសាធារណៈចំពោះការបង្កើតចលនានយោបាយថ្មីរបស់លោក។

លោកស្រីបានមានប្រសាសន៍បន្តថា "ខ្មែរដើម្បីខ្មែរ គឺជាចលនាមួយបង្កើតឡើងសម្រាប់ឱ្យគណបក្សទាំងអស់ប្តូរបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដើម្បីឈានទៅរកប្រជាធិបតេយ្យពិប្រាកដដោយគ្មានការរើសអើង និងដោយគ្មានការប្រកាន់បក្ខពួកក្នុងនាមជាមេដឹកនាំ។ ពលរដ្ឋបានរងការឈឺចាប់ដោយសារមេដឹកនាំ"។

នៅពេលទាក់ទងកាលពីម្សិលមិញលោកស្រី សុភាព បានលើកឡើងថា លោកស្រីមិនអាចរៀបរាប់អំពីការអះអាងរបស់លោកស្រីបានឡើយ។ លោកស្រីបានលើកឡើងទៀតថា អំឡុងកិច្ចប្រជុំកាលពីថ្ងៃទី៥ ខែធ្នូ លោក កឹម សុខា បានយកលោកស្រីធ្វើជាប្រភពនៃការអះអាងអំពីការប្រព្រឹត្តអំពើពុករលួយនេះ ប៉ុន្តែតាមការពិតទៅលោកស្រីមិនដឹងអ្វីឡើយ។

លោកស្រីបានពន្យល់ថា "លោក កឹម សុខា បាននិយាយថា ខ្ញុំបានប្រាប់គាត់ថា លោក សម រង្ស៊ី បានយកប្រាក់ ហើយខ្ញុំមានការតក់ស្លុតអំឡុងកិច្ចប្រជុំដែលគាត់ឆ្លើយដាក់ខ្ញុំដូច្នេះ។ ខ្ញុំមិនដឹងអ្វីនោះទេ ហេតុដូច្នេះទើបខ្ញុំបដិសេធ"។

លោក សម រង្ស៊ី ដែលបច្ចុប្បន្ននៅក្នុងប្រទេសបារាំងបានបដិសេធមិនធ្វើអត្ថាធិប្បាយលើការអះអាងនេះទេកាលពីម្សិលមិញ ហើយបានបង្វែរសំណួរទៅលោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិដែលគេមិនអាចទាក់ទងបាន។

ទោះជាយ៉ាងណា លោក មុត ចន្ថា នាយខុទ្ទកាល័យរបស់លោក កឹម សុខា បានលើកឡើងថា លោកស្រី សុភាព ដែលនៅតែជាជំនួយការរបស់លោក កឹម សុខា នៅឡើយបានប្រឌិតរឿងនេះ ហើយថា មេដឹកនាំគណបក្សសង្គ្រោះជាតិកំពុងតែពិចារណាវិធានការវិន័យ។ លោកបានមានប្រសាសន៍ថា "ខ្ញុំសូមបដិសេធយ៉ាងដាច់អហង្ការចំពោះការចោទប្រកាន់ដែលមានបំណងមិនល្អបែបនេះ។ តាមអ្វីដែលយើងបានដឹងគាត់កំពុងតែព្យាយាមរកច្រកចេញទៅកន្លែងផ្សេងហើយចោទប្រកាន់គេឯង។ យើងមិនខ្វល់ខ្វាំងពេកទេអំពីការចោទប្រកាន់នេះ ប៉ុន្តែគណបក្សនឹងចាត់វិធានការវិន័យចំពោះគាត់"។

លោក មុត ចន្ថា បានមានប្រសាសន៍បន្ថែមថា "មកទល់ពេលនេះ យើងមិនទាន់និយាយអ្វីអំពីការដកគាត់ចេញពីបក្ស ឬពីតំណែងជាជំនួយការផ្ទាល់នៅឡើយទេ ប៉ុន្តែនៅក្នុងគណបក្សមានបទបញ្ជាផ្ទៃក្នុង"។

លោកបានមានប្រសាសន៍បន្ថែមទៀតថា "ប្រសិនបើគាត់គឺជាមន្ត្រីបក្សមួយរូប និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ គាត់គួរតែបានឆ្លងកាត់ប្រព័ន្ធផ្ទៃក្នុងរបស់គណបក្ស ដើម្បីដាក់ពាក្យបណ្តឹង។ ដោយលើកឡើងរឿងអ្វីមួយជាសាធារណៈអ៊ីចឹងវារំលោភបទបញ្ជាផ្ទៃក្នុងបក្សយ៉ាងជាក់ស្តែង។ ជាសមាជិកគណបក្សមួយរូបគាត់ត្រូវតែធ្វើតាមបទបញ្ជាផ្ទៃក្នុង។ ជាការពិតណាស់គាត់មានសិទ្ធិនិយាយស្តី ប៉ុន្តែគាត់គួរតែរកមធ្យោបាយដ៏ល្អបំផុតមួយដើម្បីតបតជាជាងធ្វើការតបតដោយធ្វើការចោទប្រកាន់គ្មានមូលដ្ឋានបែបនេះ"។

លោក កែម ឡី អ្នកវិភាគនយោបាយឯករាជ្យមួយរូបដែលបង្កើតបណ្តាញសង្គម "ខ្មែរដើម្បីខ្មែរ" កាលពីខែតុលា បានលើកឡើងថា ការអះអាងរបស់លោកស្រី សុភាព គឺធ្វើឡើងជាលក្ខណៈឯកជន ហើយវាមិនឆ្លុះបញ្ចាំងអំពីទស្សនរបស់ក្រុមលោកឡើយ។

លោក កែម ឡី បានមានប្រសាសន៍ថា "ខ្ញុំមិនដឹងទេថា តើព័ត៌មាននេះពិតឬមិនពិតនោះ ព្រោះខ្ញុំមិនបានតាមដានព័ត៌មាននេះឡើយ"។ លោកបានមានប្រសាសន៍បន្ថែមថា "នៅក្នុងកិច្ចប្រជុំកាលពីម្សិលមិញខ្ញុំសង្កេតឃើញមានសមាជិកគណបក្សសង្គ្រោះជាតិយ៉ាងតិចចំនួនប្រាំនាក់មកចូលរួម។ ពួកគេមិនមែនជាសមាជិករបស់ "ខ្មែរដើម្បីខ្មែរ" ទេ នៅក្នុងនោះក៏រួមមានលោកស្រី សុភាព ដែលមិនមែនជាសមាជិក "ខ្មែរដើម្បីខ្មែរ"ផងដែរ ព្រោះគាត់នៅក្នុងគណបក្សសង្គ្រោះជាតិ។ ខ្ញុំមិនដឹងថា តើពួកគេគឺជាចារកម្មរបស់គណបក្សសង្គ្រោះជាតិឬមិនមែននោះទេ"។

ចាប់តាំងពីបង្កើតបណ្តាញសង្គម "ខ្មែរដើម្បីខ្មែរ" មកលោក កែម ឡី បានប្រឈមនឹងការចោទប្រកាន់មួយចំនួនពីគណបក្សសង្គ្រោះជាតិថា លោកមានបំណងប្រែក្លាយក្រុមរបស់លោកទៅជាគណបក្សនយោបាយមួយមុនពេលការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នាខែកុម្ភៈ ឆ្នាំ២០១៧។ លោកបានលើកឡើងថា លោកគ្រាន់តែមានបំណងលើកកម្ពស់ប្រជាធិបតេយ្យតែប៉ុណ្ណោះ។ **ស៊ុយ ឈាង**

# Assistant Kem Sokha's alleged corruption in the rescue party

**MECH AND E MM MIN EVANS | DECEMBER 29, 2014**

Assistant to one of his personal assistant, Kem Sokha, deputy party face disciplinary measures from the opposition after Assistant accused Mr. Kem Sokha on Saturday criticized President Sam Rainsy party that is linked involved in corruption.

Speaking at the first meeting of the network society, "Khmer to Khmer", led by independent political analyst Ley perfect gentleman accusations publicly with Mr. Kem Sokha last month suggested that Mr. Kem Sokha criticism during Party Standing Committee meeting conducted at the beginning of this month.

She said, "On the 5th [December] Kem Sokha criticized from about $ 30 or $ 40 Sam Russia took all $ 20 million.I can not participate in a society that is corrupt leaders ".

Gentle involvement in the protest movement in the country since the Sam Rainsy Party Khmer November 1995, did not describe her claim but praised Mr. Ley publicly for the creation of a new political movement his.

She said, "The Khmer to Khmer is a movement made up for all the parties to change its regulations to move towards democracy without discrimination and without their party as a leader. Citizens have suffered because of the leader. "

When contacted yesterday, Mrs Gentle said she can not describe her claims. She said that during the meeting on 5 December, Kem Sokha She is the source of the claims of the corruption, but in fact, she does not know anything.

She explained, "Kem Sokha said that I told him that Sam Rainsy took the money, and I was shocked during a meeting, he said to me. I do not know anything, so I declined. "

Sam Rainsy, who is currently in France, declined to comment on the claim yesterday and referred questions to Yim Sovann, a spokesman for the rescue party who could not be reached for comment.

However, Muth Chantha's Cabinet Kem Sokha said the gentleman who is still an assistant Kem Sokha's still fiction This story, and the national party leaders are considering disciplinary measures. He said, "I absolutely denied the allegations that have such a bad intention. According to what we know he is trying to find the exit to go somewhere else and charges sight. We do not care too much about the charges, but the party will take disciplinary measures against him. "

Muth Chantha said, adding, "So far, we have not said anything about his withdrawal from the party or From his position as a personal assistant, but in internal party ".

He further said, "If he is a party and a member of the Standing Committee, he should through the internal system of the party to file a complaint. Citing public something, then it violated Rules actual party. A member of a party, he must follow the regulations. Of course, he has the right to speak, but he should find the best way to counter the counter Such baseless allegations ".

Ley, an independent political analyst who create a social network "Khmer to Khmer" last October that her assertion is gentle private, and it does not reflect the team's prospects.

Ley said, "I do not know if this information is true or not, because I do not have tracking information This is it. "He added that "in a meeting yesterday I saw a member of the rescue party at least five participation. They are not a member of the "Khmer to Khmer", in which also includes gentleman who is not a member of the "Khmer Khmer ", too, because he was in Opposition. I do not know if they are a spy of the party or not, "he said.

Since the creation of social networks, "Khmer to Khmer" Ley has faced a number of allegations from the party that He intends to transform his group into a political party before the election commune council in February 2017. He said he just wanted to promote democracy. Swedish Keqiang.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី៣១ ខែធ្នូ ឆ្នាំ២០១៤

## គណបក្សទាំងពីរខ្វែងគំនិតគ្នាជុំវិញប័ណ្ណកំណត់អត្តសញ្ញាណអ្នកបោះឆ្នោត

**ដោយ គុច ណារ៉េន** | **DECEMBER 27, 2014**

គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានជាប់គាំងជាថ្មីម្តងទៀតនៅក្នុងការចរចារបស់ខ្លួនជុំវិញច្បាប់ស្តីពីការបោះឆ្នោតដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់កាលពីថ្ងៃសុក្រ នៅពេលគណបក្សទាំងពីរមិនយល់ស្របគ្នាលើរបៀបចុះឈ្មោះអ្នកបោះឆ្នោតដើម្បីបោះឆ្នោតនាពេលអនាគត។

នៅក្នុងជំនួបចរចាមួយរបស់ក្រុមការងារដែលមានពីរគណបក្សចូលរួមនៅរដ្ឋសភាគណបក្សប្រជាជនកម្ពុជា បានស្នើឡើងថា អ្នកបោះឆ្នោតគួរតែប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលរដ្ឋាភិបាលចេញឱ្យនៅតាមការិយាល័យបោះឆ្នោត ចំណែកឯគណបក្សសង្គ្រោះជាតិបានជំរុញឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ធ្វើជាអ្នកចេញប័ណ្ណកំណត់អត្តសញ្ញាណដល់អ្នកបោះឆ្នោត។

លោក គួយ ប៊ុនរឿន ប្រធានគណៈប្រតិភូរបស់គណបក្សសង្គ្រោះជាតិនៅក្នុងការចរចានេះបានមានប្រសាសន៍ថា គណបក្សប្រឆាំងចង់ឃើញការវិលទៅរកប្រព័ន្ធចុះឈ្មោះតាមបែកមជ្ឈការ ដែលធ្លាប់បានប្រើប្រាស់អំឡុងការបោះឆ្នោតឆ្នាំ១៩៩៣ ដែលទទួលបានការឧបត្ថម្ភពីអង្គការសហប្រជាជាតិ។

លោកបានមានប្រសាសន៍ថា "យើងបានស្នើសុំការព្រមព្រៀងរួមគ្នាដែលចែងថា អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតត្រូវទទួលប័ណ្ណបោះឆ្នោតចេញដោយ គ.ជ.ប."។

តែទោះជាយ៉ាងណាឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន និងជាអ្នកដឹកនាំក្រុមចរចាសម្រាប់គណបក្សកាន់អំណាច បានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាជឿថា អត្តសញ្ញាណប័ណ្ណដែលចេញដោយក្រសួងមហាផ្ទៃ គឺជាភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណគ្រប់គ្រាន់នៅថ្ងៃបោះឆ្នោតមកដល់។

លោកបានមានប្រសាសន៍ថា "សម្រាប់មាត្រានេះ យើងមិនយល់ស្របទេ។ ពួកគេចង់ចេញប័ណ្ណបោះឆ្នោតប្រភេទផ្សេងៗដូចដែលយើងធ្លាប់បានធ្វើអំឡុងសម័យអ៊ុនតាក់នៅពេលពួកគេចេញទៅចុះឈ្មោះឱ្យអ្នកបោះឆ្នោត ហើយមិនបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណទេ។ ប័ណ្ណបោះឆ្នោតគ្រាន់តែថតចម្លងព័ត៌មានទាំងអស់ចេញពីអត្តសញ្ញាណប័ណ្ណប៉ុណ្ណោះ ដូច្នេះវាអាចបណ្តាលឱ្យសរសេរឈ្មោះខុស ហើយពេលនោះប្រជាពលរដ្ឋនឹងមិនអាចបោះឆ្នោតបានទេដោយសារឈ្មោះរបស់គាត់ខុស"។

ប៉ុន្តែលោក គួយ ប៊ុនរឿន បានមានប្រសាសន៍ថា នៅក្នុងប្រទេសមានប្រជាពលរដ្ឋច្រើនណាស់ដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណនៅឡើយ ដោយសារតែការិយាធិបតេយ្យដ៏យឺតយ៉ាវ។

លោកបានមានប្រសាសន៍អំពីសំណើរបស់គណបក្សប្រជាជនកម្ពុជាថា "ប្រសិនបើក្រសួងមានសមត្ថកិច្ចជំរុញឱ្យពលរដ្ឋខ្មែរគ្រប់រូបដែលគ្រប់អាយុបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នានោះយើងនឹងពិចារណាអំពីវា។ ប៉ុន្តែរហូតមកទល់ពេលនេះប្រជាពលរដ្ឋជាច្រើនត្អូញត្អែរអំពីការលំបាកក្នុងការធ្វើអត្តសញ្ញាណប័ណ្ណ"៕

**សុខុម**

## Both parties disagreements surrounding voter identification card

KUCH NAREN | DECEMBER 27, 2014

CPP and rescue party stuck again In its negotiations around the law on The elections, which were examined to verify Friday When the two parties do not agree on how to register voters to vote in the future.

In a meeting of the working group with two parties participation in the National Assembly, the CPP proposed Elections should use government issued ID card office to vote, while the National Salvation Party urged the National Committee to organize the election (...) to be issued identification card to vote.

Mr. Bunroeun head of the delegation of the party in these negotiations , said that the opposition would like to see a return to system centralized register bombs ever used During the 1993 elections, which received support kit from the United Nations.

He said, "We have asked the joint agreement which states that all voters with voter votes in the electoral list must obtain vote out.... "

However, the Deputy Prime Minister Qin Bin and leadership the negotiating team for the ruling party, said party people believe that the identity card issued by the Ministry of Interior is the evidence identifying enough on election day arrives.

He said, "For this article, we do not agree . They want to issue various election as we ever made during the UNTAC to register [voters] and did not use ID cards. Voter card just copy all the information identity card, so it can cause the wrong name and that people will not be able to vote Because his name wrong. "

But he said Bunroeun in people Many state that does not have identity cards yet Because of slow bureaucracy.

He said the request of the CPP " If the competent ministry urged all citizens Khmer covering election put old identity cards for everyone then we will consider it. But so far this many people complained about difficult to make identity cards. "welfare.

## អ្នកឆ្លងមេរោគអេដស៍នៅក្នុងឃុំរកាបានឡើងដល់ជាង២០០នាក់

**ដោយ : ហៃ ពិសី** | **DECEMBER 29, 2014**

អាជ្ញាធរមូលដ្ឋានម្នាក់បានឱ្យដឹងកាលពីម្សិលមិញថា ឥឡូវនេះមនុស្សជាង២០០នាក់ត្រូវបានធ្វើតេស្តឈាមរកឃើញថា មានផ្ទុកមេរោគអេដស៍ អំឡុងការឆ្លងរាលដាលដ៏អាថ៌កំបាំងនៃមេរោគអេដស៍នេះនៅក្នុងឃុំរកា ខេត្តបាត់ដំបង រួមទាំងពលករចំណាកស្រុកចំនួន១៧នាក់ ដែលត្រឡប់ពីប្រទេសថៃមកស្រុកកំណើតវិញកាលពីសប្តាហ៍មុន ដើម្បីធ្វើតេស្តឈាមផងដែរ។

មេរោគអេដស៍នេះត្រូវបានដឹងថា មានការឆ្លងរាលដាលជាលើកដំបូងនៅក្នុងឃុំរកា ស្រុកសង្កែ កាលពីចុងខែវិច្ឆិកា ហើយទំហំនៃការឆ្លងរាលដាលនេះដែលបានធ្វើឱ្យមន្ត្រីសុខាភិបាលទាល់គំនិត និងធ្វើឱ្យមានការចាប់ខ្លួនគ្រូពេទ្យប្រចាំភូមិម្នាក់នោះ គឺគេនៅមិនទាន់ដឹងឱ្យបានច្បាស់លាស់នៅឡើយទេរហូតដល់ដើមខែនេះ។

នៅពេលទាក់ទងកាលពីម្សិលមិញទាំងលោក វឿន ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាលខេត្ត និងលោក ប៊ី បេងសោ ប្រធានមណ្ឌលសុខភាពឃុំរកា សុទ្ធតែបានបដិសេធមិនផ្តល់តួលេខថ្មីៗនៃចំនួនអ្នកឆ្លងមេរោគអេដស៍ឡើយ។

ប៉ុន្តែលោក សឿម ឈុំ ជំទប់ឃុំបានលើកឡើងថា មកទល់ពេលនេះគឺមានអ្នកភូមិ២០១នាក់ហើយ ដែលបានធ្វើតេស្តឈាមនៅមណ្ឌលសុខ

**តទៅទំព័រទី ១៥**

## IV infection in Roka commune to more than 200

**PISEY , OHIO | DECEMBER 29, 2014**

Local authorities said yesterday that now, more than 200 people are blood tests found to contain AIDS pandemic mystery of HIV Roka commune in Battambang province, including 17 migrant workers who returned from Thailand came home last week to test blood.

HIV has been known that the spread for the first time in the commune Roka ke in late November, and the size of the The spread, which makes health officials at the idea and make the arrest of the village doctor, They do not know yet clear until earlier this month.

When contacted yesterday Veun Bun Reth provincial head of the Department of Health and B. Column lock Roka commune health centers have declined to provide new figures Some of those infected with HIV.

But Seun Chomsky deputy commune chief said so far, there are 201 residents in the village are tested blood in the commune health centers found to have HIV infection.

Soeur Chomsky blood test was found to contain HIV, with his wife and two children , said that "statistics are up to 201 people, but the Department [of Health] does not allow this statistics".

He added that about 160 people have been confirmed in the provincial hospital on Wednesday last week, and about 40 new cases others have yet to test blood yet again.

Dek commune has also suggested that the 17 migrant workers who returned home last week and blood tests at clinics that are being found to be infected with HIV.

He further said, "There were about 20 people who had returned from Thailand, home to a blood test From December 25, so far, and 17 of them have been tested blood found to contain HIV and the other three have not been tested yet blood. They work in the fields or doing the gardening, and some of them did not return to Battambang for about 1 year ago **Continued to Page 15**

វេទិកាអ្នកអាន

ដោយ : ពុធ សុខសាន្ត

# ផ្លូវទាល់

រដ្ឋាភិបាលភ្នំពេញសព្វថ្ងៃហាក់ដូចជាដើរដល់ផ្លូវទាល់ ចំណាត់ការរបស់នាយករដ្ឋមន្ត្រីនៅតាមខេត្តក្តី ក្នុងរាជធានីភ្នំពេញក្តីចំពោះរឿងដីធ្លី ហាក់ដូចជាគ្មានប្រសិទ្ធិភាពសោះ រឿងរ៉ាវដីធ្លីបញ្ហាជាន់ត្រួតលើគ្នា ហាក់ដូចជាចាក់ស្រេះ ។

រឿងចាប់មន្ត្រីបក្សប្រឆាំង និងសកម្មជនដីធ្លីដាក់គុក មិនមានហេតុផលគ្រប់គ្រាន់សោះ រឿងហឹង្សាសកម្មជនបក្សប្រឆាំង និងសន្តិសុខសាលាក្រុងដោះស្រាយហើយ ឈប់កុំឱ្យមានបាតុកម្មតទៀត តាមទ្រឹស្តី ទឹកលើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។

ទង្វើរដ្ឋាភិបាលពេលនេះ ហាក់ដូចមិនចំណេញទេ ព្រោះរិតតែធ្វើឱ្យមតិជាតិ និងអន្តរជាតិមើលឃើញ ទង្វើខុសច្បាប់ ទង្វើហឹង្សាមកលើជនគ្មានកំហុស ទាំងលោក មាជ សុវណ្ណារ៉ា និងសកម្មជនបក្សសង្គ្រោះជាតិ មិនមានភស្តុតាងដាក់បន្ទុកទេ សកម្មជនដីធ្លីក៏មិនធ្ងន់ធ្ងរ ដល់ថ្នាក់យកទៅដាក់គុកដែរ បើចាប់រឿងស្ទះចរាចរស្រុកខ្មែរគ្មានគុកដាក់ទេ នោះរឿងសាលាក្រុងត្រូវមើលគ្រប់គ្រងកូនចៅរស់នៅទឹកលិចផ្ទះដោយលូស្ទះទឹកមិនហូរ ក្រុមហ៊ុនអភិវឌ្ឍន៍មិនរៀបចំបរិដ្ឋានត្រឹមត្រូវ បែរចាប់អ្នករងគ្រោះដាក់គុក ។

ដូចជាដើរដល់ផ្លូវទាល់មែន រឿងរ៉ាវចាក់ស្រេះគ្រប់ខេត្តក្រុង អ្នកដឹកនាំប្រទេសគ្មានមធ្យោបាយជាក់លាក់ចាត់ការ អ្នកឆ្លៀតឱកាសស្រវ៉ារកប្រយោជន៍ គិតតែខំប្រឹងប្រែងរំលោភយកប្រជាជនស្រែកយំទ្រហឹងអឹងកង នាយករដ្ឋមន្ត្រីត្រជាក់ល្ហឹមនេះមកពីគ្មានសមត្ថភាពបណ្តោយឱ្យកើតរឿងរ៉ាវចាក់ស្រេះ ច្បាប់គ្មានយុត្តិធម៌ តុលាការនៅក្រោមអំណាចបុណ្យសក្តិទឹកលុយ បើអ្នកដឹកនាំប្រទេសគេវិញ មិនចាំបាច់បញ្ហាចាក់ស្រេះ មានរឿងល្អមៗដោះស្រាយមិនចេញគេលាលែង ប្រគល់អំណាចឱ្យតំណាងរាស្ត្រដោះស្រាយ ប្រើយន្តការថ្មី ។

ឬ? មួយអាងលើនៅប្រទេសខ្មែរ មិនមានអ្នកណាអាចបញ្ជាទ័ពបាន ? រឿងគ្រប់គ្រងប្រទេសមួយ គេឱ្យអំណាចចែកគ្នាដាច់ពីគ្នា ដល់ស្រវ៉ាយកម្នាក់ឯងក្តោបអត់ជុំ មើលអត់សព្វបញ្ហាចាក់ស្រេះពលរដ្ឋខ្មែរស្រែកយំ បញ្ហាដីអត់បានបង្កបង្កើនផលរស់វេទនាដូចសម្លាប់គាត់ឱ្យគាត់ធ្លាក់នរកទាំងរស់ ។

តើមាននាយករដ្ឋមន្ត្រីណាខ្លះ ដែលមានសេចក្តីសុខលើគំនរទុក្ខពលរដ្ឋខ្មែរខ្លួនឯង បើសព្វថ្ងៃរដ្ឋអំណាចថ្នាក់ភូមិឃុំខេត្ត ហាក់ដូចជាយកច្បាប់ទ្រាប់អង្គុយ តើនៅដឹកនាំប្រទេសទាំងអសមត្ថភាពរហូតដល់ពេលណា ។

ព្រៃឈើរលាយហិនហោចអស់ តំបន់អភិវឌ្ឍន៍ចៅហ្វាយក្រុងជាមួយក្រុមហ៊ុនរួមគំនិតគ្នាគាបរាស្ត្របួន់រាស្ត្រ មនុស្សគ្មានគំនិតរស់នៅដីតូចសង់ខ្ទមល្មមក៏ចេះតែរស់ទៅ អ្នកមានគំនិតប្រឹងប្រែងរិះថាំ សន្សំទិញដី ពង្រីកផ្ទះ សង្ឃឹមចាស់ទៅមានផ្ទះ មានដីចែកឱ្យកូនមានមុខរបរសមរម្យរស់ថ្លៃថ្នូរដូចគេឯង ។

តែសម័យស្តេចចោរ វេទនារាស្ត្រ សាលាក្រុងក្រុងហ៊ុនតាមប្លន់យកចែកគ្នាតាមចិត្តលោភលន់ អត់ខ្មាស់ អត់មានអាសូររាស្ត្រខំរកលុយញើសហូរដល់កែងប្រឹងស៊ូ អត់ឃ្លានហេតុអីច្បាប់ស្រុកខ្មែរនៅលើមាត់អ្នកមានអំណាច សប្បាយហ៊ឺហារហ៊ឹកហាក់លើគំនរទុក្ខរាស្ត្រ ។

រាស្ត្រខ្មែររងកម្មខ្លាំងណាស់ ដែលមានមេដឹកនាំប្រទេស អសមត្ថភាពហើយធ្វើមិនដឹងខ្លួន ឥឡូវចំណាត់ការគ្មានប្រសិទ្ធិភាពហើយរីករវជិតពេញផ្ទៃប្រទេស ហើយនៅមិនដឹងខ្លួនទៀត ។

គួរឱ្យអាសូរអ្នកទើបនឹងគោង ដើម្បីឱ្យបានពែរស៊ីនឹងគេមិនយល់ ឬក៏ធ្វើមិនយល់ថារដ្ឋអំណាចបក្ស CPP វាអស់តម្លៃទៅហើយ ឬមួយថាគោងកន្ទុយ CPP មានគេគោត មានគិតទេថា ឧក្រិដ្ឋជនប្រឆាំងមនុស្សជាតិនៅតែថ្ងៃគេអូសយកទៅ ICC ព្រោះនៅលើពិភពលោកយើងនេះ បើមនុស្សធ្វើអាក្រក់បានផលល្អ រហូតមនុស្សគេឈប់ធ្វើល្អហើយ ។

តែកុនក្តី ល្ខោនក្តី មនុស្សអាក្រក់តែងតែឈ្នះគ្រាដំបូង តែជិតចប់ទើបមនុស្សល្អឈ្នះវិញ ឈប់ស្រមៃថាគោង CPP ប្រសើរទៅប្រយ័ត្នជាន់ដានចោរ ៕

**ជ័យជំនះពិតប្រាកដរបស់មនុស្ស គឺវិនាទីចុងក្រោយនៃជីវិត**



តមកពីទំព័រទី ១៣ អ្នកឆ្លងមេរោគអេដស៍នៅក្នុងឃុំរកាបានឡើង...

ភាពឃុំរកឃើញថាមានឆ្លងមេរោគអេដស៍។

លោក សឿម ឈុំ ដែលត្រូវបានធ្វើតេស្តឈាមរកឃើញថា មានផ្ទុកមេរោគអេដស៍ជាមួយនឹងប្រពន្ធរបស់លោក និងចៅពីរនាក់ទៀតនោះបានមានប្រសាសន៍ថា "ស្ថិតិនោះគឺឡើងដល់២០១នាក់ហើយ ប៉ុន្តែក្រសួងឱ្យសុខាភិបាលមិនអនុញ្ញាតឱ្យបញ្ចេញស្ថិតិនេះទេ"។

លោកបានបន្ថែមថា អ្នកឆ្លងប្រហែល១៦០នាក់ត្រូវបានបញ្ជាក់នៅមន្ទីរពេទ្យបង្អែកខេត្តកាលពីថ្ងៃពុធសប្តាហ៍មុន រីឯករណីថ្មីប្រហែល៤០នាក់ទៀតនៅមិនទាន់ធ្វើតេស្តឈាមម្តងទៀតនៅឡើយទេ។

ជំទប់ឃុំរូបនេះក៏បានលើកឡើងផងដែរថា ពលករចំណាកស្រុកទាំង១៧នាក់ដែលបានត្រឡប់មកស្រុកកំណើតកាលពីសប្តាហ៍មុន និងដែលបានធ្វើតេស្តឈាមនៅមណ្ឌលសុខភាពនោះគឺសុទ្ធតែត្រូវបានរកឃើញថា មានឆ្លងមេរោគអេដស៍។

លោកបានមានប្រសាសន៍បន្ថែមទៀតថា "មានមនុស្សប្រហែល២០នាក់ដែលបានត្រឡប់ពីប្រទេសថៃមកស្រុកកំណើតវិញ ដើម្បីធ្វើតេស្តឈាមចាប់ពីថ្ងៃទី២៥ ខែធ្នូ រហូតមកទល់ពេលនេះ ហើយក្នុងចំណោមពួកគេមាន១៧នាក់ត្រូវបានធ្វើតេស្តឈាមរកឃើញថា មានផ្ទុកមេរោគអេដស៍ រីឯបីនាក់ផ្សេងទៀតនៅមិនទាន់បានធ្វើតេស្តឈាមនៅឡើយទេ។ ពួកគេធ្វើការនៅចម្ការ ឬធ្វើជាអ្នកថែសួន ហើយពួកគេមួយចំនួនមិនបានត្រឡប់មកខេត្តបាត់ដំបងវិញអស់រយៈពេលប្រហែល១ឆ្នាំមកហើយ ហើយមួយចំនួនទៀតអស់រយៈពេលត្រឹមតែប្រហែល១ខែប៉ុណ្ណោះ"។

ក្រុមមន្ត្រីបានបន្ទោសការឆ្លងរាលដាលនៃមេរោគអេដស៍នេះលើលោក យ៉ែម ជ្រិន គ្រូពេទ្យគ្មានអាជ្ញាប័ណ្ណដែលផ្តល់ការព្យាបាលដល់អ្នកភូមិជាច្រើននាក់នៅក្នុងឃុំនេះ។ កាលពីថ្ងៃច័ន្ទ សាលាដំបូងខេត្តបានចោទប្រកាន់លោក យ៉ែម ជ្រិន ពីបទមនុស្សឃាតដែលអាចជាប់ពន្ធនាគារអស់មួយជីវិត ហើយបានបញ្ជូនគាត់ទៅមន្ទីរខេត្ត។

លោក សឿម ឈុំ បានមានប្រសាសន៍បន្តទៀតថា "អ្នកដែលកំពុងធ្វើការនៅក្នុងប្រទេសថៃបានមកស្រុកកំណើតវិញដើម្បីធ្វើតេស្តឈាម ព្រោះពួកគេសុទ្ធតែត្រូវបានគ្រូពេទ្យឱ្យលោក យ៉ែម ជ្រិន" ព្យាបាលឱ្យ។ លោកបានបន្ថែមថា ដោយសារតែការឆ្លងរាលដាលនេះត្រូវបានគេដឹងយ៉ាងសុសសាយនោះ លោកក៏ចាប់ផ្តើមទទួលរងនូវពាក្យសម្តីអំពីការរើសអើងផងដែរ។

លោកបានមានប្រសាសន៍ថា "មនុស្សបីនាក់បានប្រាប់ខ្ញុំថា នៅពេលពួកគេបានទៅផ្សារ ពួកគេបានឮគេនិយាយអំពីការឆ្លងរាលដាលនៃមេរោគអេដស៍នេះ ហើយថា គួរតែមានការប្រុងប្រយ័ត្នចំពោះអ្នកភូមិរកា។ មនុស្សម្នាក់ក្នុងចំណោមអ្នកទាំងបីនាក់នេះបានប្រាប់ខ្ញុំថា ជាងកាត់សក់នឹងមិនកាត់សក់ឱ្យគាត់ទេ ព្រោះគាត់មកពីឃុំរកា"។

លោក អ៊ុំ សុភាព ប្រធានអង្គការ Khana ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តល់ការគាំទ្រ និងទប់ស្កាត់មេរោគអេដស៍បានលើកឡើងថា អ្នកភូមិផ្ទុកមេរោគអេដស៍ដែលប្រឈមនឹងការរើសអើងបានធ្លាក់ទឹកចិត្តយ៉ាងឆាប់រហ័ស។

លោកបានមានប្រសាសន៍ថា "ពួកគាត់មិនចង់ចេញទៅក្រៅទេ ពួកគាត់ខ្មាស់គេហើយពួកគាត់មានអារម្មណ៍ថា ខ្លួនមិនដូចគេ។ ពួកគាត់មានការលំបាកក្នុងការរស់នៅ។ នៅពេលពួកគាត់ទៅណាមកណាគេហៅពួកគាត់ថា អ្នកភូមិអេដស៍ ឬគ្រួសារអេដស៍"៕ **ស៊ុយ ឈាង**

Continued from page 03

## IV infection in Roka commune to more than 200

and some for only about 1 month. "

Officials blame the spread of HIV on the editing Yem unlicensed physicians who provide treatment to villagers Many people in this commune. Provincial court on Monday accused Daniel editing for the murder, which can be put in jail for life, and sent him to the hospital.

Mr Suen said Chomsky said that "those who are working in Thailand, home to test blood because they are doctors [editing Yem] "treatment. He added that due to the spread of this was known abroad, he began to suffer speech discrimination.

He said, "Three people have told me that when they went to the market, they've heard about the infection This spread of HIV, and that ought to be careful for the villagers maintain. One of the three people told me that the hair will not cut his hair because he Roka commune ".

Um Sopheap Khana local non-governmental organization that provides support and prevent HIV raised villages infected with HIV face discrimination depression quickly.

He said, "They do not want to go out, but they were ashamed, and they feel that they do not like them. They are hard to live. When they called their residents with HIV or AIDS, family. "Swedish Keqiang .

SAVINGS WITH MASS APPEAL
DRIVERS WHO SWITCHED SAVED
$498
NATIONAL ANNUAL AVERAGE
**Want to save on car insurance? Call me first.**
It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com
Allstate. You're in good hands.
Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.

**MARCOTTE LAW FIRM**
**ក្រុមហ៊ុនមេធាវី Marcotte**
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
• សេចក្តីអន្តរាយដល់បុគ្គល
• ច្បាប់ធានារ៉ាប់រង
• សំណងបុគ្គល
• ការរំលោភបទព្រហ្មទណ្ឌ
• ពិការភាពដោយសន្តិសុខសង្គម
• គ្រោះថ្នាក់ចរាចរណ៍
• បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
• គ្រោះថ្នាក់នៅការដ្ឋាន
• ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
• បំណុលអចលទ្រព្យ
• បណ្តឹងវិវាទទូទៅ
• បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**
(978) 458-1229
www.marcottelawfirm.com

# វប្បធម៌សន្ទនានៅព្រះរាជាណាចក្រកម្ពុជា


លឹម គិមយ៉ា

នៅថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០១៤នៅវិមានរដ្ឋសភា ។ សភាពេញអង្គបានប្រជុំសំរេចស្តីពីសេចក្តី ស្នើវិសោធនកម្ម ជំពូកទី១២ប្រការ៤៨ ថ្មី(ពីរ) ទៅជំពូកទី១២ ប្រការ ៤៨ ថ្មី (បី) ។

សេចក្តីស្នើវិសោធនកម្មជំពូកទី១២ ប្រការ ៤៨ថ្មី (ពីរ) ពីបទបញ្ជាផ្ទៃក្នុងរបស់សភា គឺប្រសូតចេញពីសន្យាគ្នារវាងគណបក្សសង្គ្រោះជាតិ និងប្រជាជនកម្ពុជាកាលពីថ្ងៃទី២២ ខែកក្កដាឆ្នាំ ២០១៤ បានយល់ស្របចុះសំរុងគ្នា ហើយនឹងឆ្លើយតបទៅនឹងវប្បធម៌សន្ទនា។

ឥឡូវនេះអ្នកនយោបាយខ្មែរជ្រើសរើសយកវប្បធម៌សន្ទនា ដែលពីដើមមុនអាណត្តិទីប្រាំនេះ គ្មានទេវប្បធម៌សន្ទនានោះមានតែវប្បធម៌ហឹង្សា និងកំញើញ ។ យើងសង្ឃឹមយ៉ាងមុះមុតថា ប្រទេសកម្ពុជានឹងទៅរកលទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដដែលប្រទេសជឿនលឿនមាននោះ ។ យើងធ្វើសំណូមពរសូមឱ្យការសង្ឃឹមរបស់យើងនឹងក្លាយទៅជាការពិតមិនត្រឹមតែជាការសង្ឃឹមតែប៉ុណ្ណោះទេ ។

ជាដំបូងយើងសុំឱ្យរាជរដ្ឋាភិបាលដោះលែងប្រជាពលរដ្ឋដែលជាប់ឃុំឃាំងដោយសារតែគ្នាបញ្ចេញមតិដើម្បីការពារសិទ្ធិរបស់គ្នា ។ បើមិនយ៉ាងដូច្នេះទេ យើងពិបាកនឹងជឿថា នឹងមានវប្បធម៌សន្ទនាគ្នាពិតប្រាកដមែននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

វប្បធម៌ហឹង្សា និងកំញើញដែលយើងស្តាយដូចកាលឆ្នាំ២០០៨ ដែលសៀមមកឈ្លានពានប្រទេសយើងនៅតាមតំបន់ព្រះវិហារនាយករដ្ឋមន្ត្រីមិនបានស្តាប់យោបល់ប្រធានបក្ស សម រង្ស៊ី និងសិទ្ធិមនុស្សដែលសុំឱ្យរាជរដ្ឋាភិបាលលើករឿងនេះទៅតុលាការអន្តរជាតិទីក្រុងឡាអេទេ ដោយសារតែគ្មានវប្បធម៌សន្ទនា ។ តែសម្តេចនាយករដ្ឋមន្ត្រីបានចំអក ហើយឱ្យលើកទ័ពទៅទប់ជាមួយសៀមវិញ ។ នៅពេលនេះយើងគ្មានចំនួនពិតប្រាកដពីការខាតបង់ជីវិតកងទ័ពប្រជាពលរដ្ឋ ថវិកា ព្រៃឈើនោះទេ យើងដឹងថាដំណោះស្រាយតាមកំលាំងទ័ពអត់បានអ្វីទាំងអស់ឃើញតែពីខាតបង់ ។ ហើយរាជរដ្ឋាភិបាលក៏ត្រឡប់មកយកតាមយោបល់ប្រធានបក្ស សម រង្ស៊ី និងសិទ្ធិមនុស្សទៅវិញ ។ ឃើញថា បានជោគជ័យកាលពីថ្ងៃទី១១ខែវិច្ឆកា ឆ្នាំ២០១៣ ដែលតុលាការអន្តរជាតិទីក្រុងឡាអេបានកាត់ឱ្យខ្មែរឈ្នះ ។ តែជ័យជំនះនេះរាជរដ្ឋាភិបាលខ្មែរ ដូចជាមិនបានឱ្យសៀមអនុវត្តតាមសេចក្តីសំរេចរបស់តុលាការទេ ដែលខ្មែរខំធ្វើការដោយចំណាយអស់ជាច្រើនម៉ឺនដុល្លារ ។

បើប្រសិនជាកាលនោះសម្តេចនាយករដ្ឋមន្ត្រីប្រកាន់យកវប្បធម៌សន្ទនាប្រហែលជាយើងមិនខាតបង់ជីវិតថវិកា ព្រៃឈើនោះទេ ។

សេចក្តីស្នើវិសោធនកម្មជំពូកទី១២ ប្រការ ៤៨ ថ្មី (ពីរ) ទៅប្រការ៤៨ ថ្មី (បី) ពីបទបញ្ជាផ្ទៃក្នុងរបស់សភាជាការត្រឹមត្រូវល្អតាមផ្លូវនយោបាយពិតប្រាកដមែនហើយ ។ តែមានបញ្ហាបច្ចេកទេសបន្តិចដែលអ្នកចរចា និងសរសេរ ដូចជាមិនបានចាប់អារម្មណ៍មានវគ្គខ្លះមិនសមស្របនឹងគ្នា ។ ការដែលយើងលើកមកនេះ ដោយយើងមានការព្រួយបារម្ភខ្លាចនិសិត្សជំនាន់ក្រោយនឹងធ្វើការសិក្សាស្រាវជ្រាវពីបទបញ្ជាផ្ទៃក្នុងនេះ ថាការសរសេររបៀបអស់នេះមានកំរិត ហើយសួរថាតើការសិក្សា និងចំណេះចេះដឹងរបស់តំណាងរាស្ត្រនៅសម័យនោះអ៊ីក៏ទាបម្ល៉េះ! ។

**ពីរចំណុចយើងនឹងលើកជូនមកពិចារណា :**

**ទី១**"ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី២៥(ម្ភៃប្រាំ) ភាគរយឡើងទៅមានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា ។ ប្រធានក្រុមមតិភាគតិចជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ ។ ប្រធានក្រុមមតិភាគតិចមានឋានៈស្មើនាយករដ្ឋមន្ត្រី" ។

នៅពេលនេះបញ្ហាអត់មានចោទទេ តែទៅអនាគត បើប្រសិនណាជាគណបក្សនយោបាយក្រៅរាជរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាមិនបានដល់២៥ (ម្ភៃប្រាំ) ភាគរយ តើយើងគិតយ៉ាងដូចម្តេច? ប្រហែលជាអត់គូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទេ! ។ បើប្រសិនណាជាទៅអនាគត បើមានបក្សច្រើននៅក្នុងសភានៅក្រៅរាជរដ្ឋាភិបាល គួរណាតែឱ្យអ្នកដឹកនាំបក្សទាំងអស់មានមធ្យោបាយសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ ។ ច្បាស់ជាបានផលប្រយោជន៍ជាងបក្សតែមួយ ។ហើយប្រធានក្រុមភាគតិចមិនច្បាស់ជាឈ្លាសវៃ និងមានគំនិតជាងមេបក្សផ្សេងៗទៀតដែរ ។ ហើយជៀសវាងការឃុបឃិត ឬពាក្យចាមអារាមពីគ្រប់មជ្ឈដ្ឋាននានា ដែលយើងធ្លាប់បានឮមកហើយ ។

**ទី២** បើគណបក្សណាមួយមានតំណាងរាស្ត្រ៥ភាគរយ គឺ៦.១៥នាក់ ដោយមនុស្សចែកមិនដាច់ត្រូវថា៧នាក់ បានអាចមានជាអង្គភាពជាគណបក្ស ហើយរដ្ឋសភាផ្តល់មធ្យោបាយឱ្យធ្វើសកម្មភាព ។ តែដើម្បីបង្កើតជាក្រុមបានទាល់តែ១០នាក់ ។ ហេតុនេះដើម្បីឱ្យមានសមធម៌ចំពោះគណបក្សតូចៗត្រូវតែប្រើអង្គភាពគណបក្សដែលមានចំនួនតំណាងរាស្ត្រយ៉ាងតិចតែ៥ភាគរយជាជាងកំណត់យក១០រូប ដើម្បីបង្កើតជាក្រុមនៅសភា។

បើយើងចង់ទុកចំនួនតំណាងរាស្ត្រលើសពី ១០រូប ដើម្បីបង្កើតជាក្រុមយើងគួរតែតំឡើងចំនួនពី៥ភាគរយទៅ៨ភាគរយទៅ ។ បើយើងចង់ទុកចំនួនតែ៥ភាគរយ គឺត្រូវតែចុះចំនួនពី១០ រូប មកត្រឹមតែ៧រូបបានហើយ ។

ត្រង់នេះ យើងជឿថា អ្នកដែលមានគំនិត ៥ភាគរយនេះ គឺយកឧទាហរណ៍តាមប្រទេសអាល្លឺម៉ង់ដោយមិនបានដឹងច្បាស់ថា សភាអាល្លឺម៉ង់អត់បានកំរិតពីចំនួនតំណាងរាស្ត្រទេ ហើយគេកំណត់យ៉ាងតិចតែ៥ភាគរយដើម្បីបង្កើតជាក្រុមមួយតែប៉ុណ្ណោះ ។

**លឹម គិមយ៉ា**

*តំណាងរាស្ត្រ មណ្ឌលកំពង់ធំ*

*សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា*

**សូមភ្ជាប់មកជាមួយនូវប្រការ៤៨ថ្មី (បី) :**

**ជំពូកទី១២ថ្មី**

អំពីរបៀបប្រជុំ និងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ

**ប្រការ ៤៨ ថ្មី (បី)**

តំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី៥(ប្រាំ) ភាគរយឡើងទៅត្រូវរៀបចំថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយតាមគណបក្សនយោបាយនីមួយៗ ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយមានសមាសភាពយ៉ាងច្រើន៣(បី) រូប ។ បញ្ជីរាយនាមរបស់ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយត្រូវផ្ញើជូនប្រធានរដ្ឋសភា ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយមានភារកិច្ចដូចខាងក្រោម :

-ធ្វើការដឹកនាំតំណាងរាស្ត្ររបស់គណបក្សដើម្បីធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅស្របតាមកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស។

-ធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅដោយរលូន និងធានាបាននូវផលប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋ ។

រដ្ឋសភាត្រូវផ្តល់ឱ្យថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយនូវមធ្យោបាយសមស្របដើម្បីថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ តទៅទំព័រទី ២០

KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
អ្នកនិពន្ធកិត្តិយស Contributed Writers:
Kim Phien, Richard Howe,Jr.
ច្នៃសោភ័ណភាពកាសែត Design Artist
Heng Chhunleng
នាយករដ្ឋបាល Office Manager 978-677-7163
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# ស្ត្រីគួរទៅពិនិត្យរោគមហារីកសុដន់



ការសិក្សាថ្មីមួយបានបង្ហាញថា ស្ត្រីឆាប់ទៅពិនិត្យរកជំងឺមហារីកសុដន់នៅមុនអាយុ២៥ឆ្នាំអាចជួយដល់ស្ត្រីពាក់ព័ន្ធនឹងជំងឺមហារីកខ្ពស់ ។

អ្នកស្រីវេជ្ជបណ្ឌិត ជេនីលី អ្នកនិពន្ធដែលមានជំនាញផ្នែកសុដន់នៅមន្ទីរពេទ្យរដ្ឋម៉ាឈូសេតបានឱ្យដឹងថា អត្រាមរណៈនៃជំងឺមហារីកសុដន់នឹងថយចុះ បើយើងបានទៅពិនិត្យទាន់ពេលវេលា ។

បើធៀបនឹងស្ត្រីដែលមិនបានទៅពិនិត្យអ្វីទាំងអស់ជាប្រចាំឆ្នាំដែលមានអាយុចាប់ពី២៥ឆ្នាំ គឺអាចពន្យារជីវិតពួកគេចាប់ពី១,៣ទៅ១,៨ឆ្នាំ ។ ការពិនិត្យស្តែនរកជំងឺមហារីកសុដន់រៀងរាល់៦ខែម្តងបានពន្យារជីវិតចាប់ពី១,៥ ទៅ១,៧ឆ្នាំ ។

បើបានពិនិត្យរកជំងឺមហារីកសុដន់ពីអាយុ២៥ឆ្នាំអាចធ្វើឱ្យស្ត្រីទទួលបានប្រយោជន៍ដល់សុខភាព និងភាពងាយស្រួលក្នុងការព្យាបាល ប៉ុន្តែចំពោះស្ត្រីភាគច្រើនដែលបានទៅពិនិត្យរកជំងឺនេះនៅវ័យជាង៣០ឆ្នាំ ក៏អាចហុចផលល្អដូចគ្នានេះដែរ ៕



# តេស្តវិនិច្ឆ័យស្ត្រីឆាប់អស់រដូវ

តាមធម្មតាមិនមានតេស្តជាក់លាក់ចាំបាច់ដើម្បីកំណត់អំពីការអត់មានរដូវនោះទេ ប៉ុន្តែពេលខ្លះស្ត្រីដែលមានរោគសញ្ញានៃការអស់រដូវ និងមានរដូវមិន ទៀងទាត់ អាចត្រូវបានគេធ្វើតេស្តដើម្បីកំណត់ពីមុខងារនៃក្រពេញអូវែរបស់ពួកគេ។

ការធ្វើតេស្តដើម្បីញែកចេញពីការមានផ្ទៃពោះ ឬមូលហេតុដទៃទៀត នៃការខកខានមិនមករដូវដែលមានដូចជាជំងឺនៃក្រពេញទីរ៉ូអ៊ីតមួយចំនួន ។

ជារឿយៗកម្រិតនៃអ័រម៉ូន FSH (folliecle-stimulating hormone) ត្រូវបានគេវាស់នៅក្នុងឈាមដើម្បីកំណត់ថា តើក្រពេញអូវែរបស់គាត់កំពុងតែធ្វើការល្អយ៉ាងណា ។

អ័រម៉ូន FSH ភ្ញោចលើក្រពេញអូវែឱ្យផលិតអ័រម៉ូនអឺស្ត្រូសែនដូចនេះកម្រិតនៃអ័រម៉ូនកើនឡើងនៅពេលដែលកម្រិតអ័រម៉ូនថយចុះ ។ កម្រិតអ័រម៉ូន FSH ដែលកើនឡើងលើសពី៤០មុី.មល ត្រូវបានគេចាត់ទុកថា ជាលក្ខណៈនៃការអស់រដូវ ។

កម្រិតនៃអ័រម៉ូននៃក្រពេកអូវែក៏អាចត្រូវបានគេពិនិត្យផងដែរ នៅពេលដែលវាទាបជាង៣២ផង.មល ក្នុងមួយមីលីលីត្រ គឺបង្ហាញថា ស្ត្រីបានអស់រដូវហើយ ៕




## ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

## Rathe´s Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

## ANGKOR AUTO SERVICE,INC.

## ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance



BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

ភូមិសាស្ត្រខេត្តរតនគិរី
ដោយ សាគូ សាមុត

# ជំរឿនប្រជាជនឆ្នាំ១៩៩៨ បានឱ្យដឹងថា ជនជាតិភាគតិចមាន៨០ភាគរយខ្មែរមាន១៩ភាគរយ

ជំរឿនប្រជាជនឆ្នាំ១៩៩៨ បានឱ្យដឹងថា ជនជាតិភាគតិចមាន៨០ភាគរយ ខ្មែរមាន១៩ភាគរយ ។ តែមកដល់ពេលឥឡូវនេះ តួលេខបានប្តូរបញ្ច្រាសវិញ ដោយខ្មែរ និងយួនមកតាំងទីរស់នៅជាច្រើន ។
**ជនជាតិភាគតិចមាន :** ទំពួន ចារ៉ាយ គ្រឹង ព្រៅ កាចុក ក្រវិត កួយ ឡង់, **ជាតិពន្ធុដទៃទៀត :** ខ្មែរ ឡាវ គីញ(យួន) ចាម ចិន ។
ដកស្រង់ពីសៀវភៅបោះពុម្ពផ្សាយនៅភ្នំពេញ ភូមិសាស្ត្រប្រទេសកម្ពុជា, **ជូនភ្ជាប់មក :** ខេត្តរតនគិរី (ភូមិសាស្ត្រ-ប្រវត្តិសាស្ត្រ)

## ៣- ខេត្ត រតនគិរី



***ផ្ទៃដី៖*** *១០ ៧៨២គម²* ***ប្រជាជន៖*** *១៥០ ៤៦៦នាក់*
***ក្រុងបានលុង៖*** *២៨ ៩៨២នាក់* ***ចំនួនស្រុក៖*** *៨* ***ចំនួនឃុំ៖*** *៤៦*
***ចំនួនភូមិ៖*** *២៤០* ***ដង់ស៊ីតេប្រជាជន(មនុស្ស/គម²)៖*** *១៤នាក់*

***ខេត្តរតនគិរី***ជាខេត្តឋិតនៅទិសឦសាននៃប្រទេសកម្ពុជា។ ខេត្តនេះមានព្រំប្រទល់ខាងជើងជាប់ប្រទេសឡាវខាងកើតជាប់ប្រទេសវៀតណាម ខាងត្បូងជាប់ខេត្តមណ្ឌលគិរី និងខាងលិចជាប់ខេត្តស្ទឹងត្រែង។







***ខេត្តរតនគិរី***ស្ថិតនៅខ្ពង់រាបទិសឦសានប្រទេស។ ខ្ពង់រាបនេះជាគែមខាងលិចនៃប្រជុំភ្នំកន្ទីនៃប្រទេសវៀតណាម។ តាំងពីយូរណាស់មកហើយតំបន់នេះមាន***អ្នកស្រុកភ្នំ***រស់នៅ។ តំបូងដើមឡើយ ខេត្តនេះស្ថិតនៅមហានគរខ្មែរ តែក្រោយមកបានធ្លាក់ចូលដៃសៀម លាវ អណ្ណាមនិងបារាំងអាណានិគម។ ***ផែនទីភ្ជាប់មកនេះឆ្នាំ១៨៨៦*** បង្ហាញពីខេត្តរតនគិរីគ្រប់គ្រងដោយសៀម-លាវ បន្ទាប់មកបានប្រគល់ឲ្យបារាំងតាមកិច្ចសន្យាឆ្នាំ១៩០២និងឆ្នាំ១៩០៧។ មកដល់ឆ្នាំ១៩៥៩ខេត្តនេះស្ថិតនៅជាមួយខេត្តស្ទឹងត្រែង។ ឆ្នាំ១៩៦០សម្តេចន.សីហនុបានបំបែកជាពីរដើម្បីធ្វើអភិវឌ្ឍន៍។ ខេត្តនេះមានផ្លូវលំហូជីមិញឆ្លងកាត់នៅទសវត្ស៦០-៧០។ នៅឆ្នាំ១៩៧០ទ័ពអាមេរិកបានដេញវាយវៀតកុងទម្លាក់គ្រាប់បែកលើខេត្តនេះ។



*សណ្ឋានដីប្រទេសកម្ពុជា មាន ទំនាបកណ្តាល ព័ទ្ធជុំវិញដោយភ្នំនិងខ្ពង់រាប គឺភ្នំក្រវាញនៅនិរតី ភ្នំដងរែកនៅខាងជើង ខ្ពង់រាបខាងជើង* ***ខ្ពង់រាបខាងកើត និងឦសាន***

**រដ្ឋបាល** ***ខេត្តរតនគិរី*** *មានស្រុកចំនួន៨- ក្រុង១ - ឃុំ-សង្កាត់ចំនួន ៤៩ ៖*

**១-ស្រុកអណ្តូងមាស** ➤ *ម៉ាលិក ញ៉ាង តាឡាវ (៣ឃុំ)*
**២-ស្រុកបរកែវ** ➤ *កក់ កិះចុង ឡាមីញ លុងឃុង សើ៊ង ទីងចាក់ (៦ឃុំ)*
**៣-ស្រុកកូនមុំ**➤*សិរីមង្គល ស្រែអង្គ្រង តាអង តឺន ត្រពាំងច្រេស ត្រពាំងក្រហម (៦ឃុំ)*
**៤-ស្រុកលំផាត់** ➤ *ជ័យឧត្តម កាឡែង ល្បាំង១ ល្បាំង២ បាតាង សេដា (៦ឃុំ)*
**៥-ស្រុកអូរជុំ** ➤ *ចាអ៊ុង ប៉ូយ ឯកភាព កាឡៃ អូរជុំ សាមគ្គី ល្អក់ (៧ឃុំ)*
**៦-ស្រុកអូរយ៉ាដាវ** ➤ *បរខាំ លំជ័រ ប៉ក់ញ៉ៃ ប៉ាតេ សេសាន សោមធំ យ៉ាទុង (៧ឃុំ)*
**៧-ស្រុកតាវែង** ➤ *តាវែងលើ តាវែងក្រោម (២ឃុំ)*
**៨-ស្រុកវើនសៃ** ➤ *ប៉ុង ហាត់ប៉ក់ កាចូន កោះប៉ង់ កោះពាក្យ កុកឡាក់ ប៉ាកាឡាន់ ភ្នំកុក វើនសៃ (៩ឃុំ)*
**៩-ក្រុងបានលុង** ➤ *កាចាញ ឡាបានសៀក យក្សឡោម (៣សង្កាត់)*

----------------

**សណ្ឋានដីប្រទេសកម្ពុជា** *មាន ទំនាបកណ្តាល ព័ទ្ធជុំវិញដោយភ្នំនិងខ្ពង់រាប គឺភ្នំក្រវាញនៅនិរតី ភ្នំដងរែកនៅខាងជើង ខ្ពង់រាបខាងជើង* ***ខ្ពង់រាបខាងកើត និងឦសាន***។

### ខ្ពង់រាបខាងកើត និង ឦសាន

- ***ខ្ពង់រាបនៃខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ*** *មានលក្ខណៈដូចគ្នានឹងខ្ពង់រាបខាងជើងដែរ ហើយនៅដាច់ពីខ្ពង់រាបនោះ ដោយសារជ្រលងនៃទន្លេមេគង្គ គឺជាតំបន់មានរាងតុ ជាតំបន់ល្បាប់ចាស់ប្រកបទៅដោយព្រៃរបោះ តែនៅទីនោះពុំសូវសំបូរកូនភ្នំដាច់តែឯងទេ។*
- ***ខ្ពង់រាបនៃខេត្តកំពង់ចាម*** *ជាខ្ពង់រាបមួយយ៉ាងទេរទៅឦសាន ហើយមានរយៈកំពស់២០០ម ខាងនិរតីជាប់នឹងទំនាបកណ្តាល។ ខ្ពង់រាបទាំងនោះ ក៏មានរាងតុនិងប្រកបដោយល្បាប់ចាស់និងថ្មបាសាល់ ដែលមានស្រទាប់លើពុកជាដីក្រហមទៅហើយ។ ទីនោះដែលមានទួលថ្មបាសាល់ចំនួនបួនគ្របពីលើថ្មក្រែ បានក្លាយជាចំការដំណាំធំៗ៖ ចំការលើ មេមត់ និងស្នួល។ តំបន់ដីក្រហមទាំងនោះ សុទ្ធសឹងជាចំការកៅស៊ូនិងចំការដំណាំធំៗ។*
- ***ខ្ពង់រាបនៃខេត្តរតនគិរី****ជាគែមខាងលិចនៃប្រជុំភ្នំកន្ទីនៃប្រទេសវៀតណាមកណ្តាល។ ខ្ពង់រាបនេះដាច់ជាច្រើនផ្នែកដោយទន្លេមេគង្គ។ នៅចន្លោះទន្លេសាបនិងទន្លេស្រែពកមានខ្ពង់រាបបកែវដែលជាខ្ពង់រាបថ្មបាសាល់គ្របដណ្តប់ដោយរីយូលីត Rhyolite ហើយមានកំពូលខ្ពស់បំផុតមិនលើសពី៥០០ម រីឯច្រាំងខ្ពង់រាបនេះជាថ្មគ្រីស្តាល្លាំង។ នៅចន្លោះទន្លេកុងនិងទន្លេសេសាន មានប្រជុំភ្នំមួយដែលមានកំពស់មធ្យមស្ថិតជាព្រំប្រទល់រវាងប្រទេសខ្មែរនិងប្រទេសឡាវ។ ភ្នំដែលមានកំពូលខ្ពស់លើសពី៧០០ម. គឺភ្នំពោងពាយ(៨១៦ម.) ភ្នំគ្រង់(៧០១ម.)។*

**តទៅលេខក្រោយ**


# ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
# Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852
**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.
ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

*លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។*

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

# ព្រះសមណៈ សឺនហាយ ជានរណា?

**ដោយ: បញ្ញ សីលា**

**ព្រះសង្ឃព្រះនាម សឺន ហាយ ជានរណា?**

យើងមានក្តីក្រៀមក្រំរំលឹកដល់ព្រះនាមសមណអង្គនេះ ព្រោះព្រះសង្ឃខ្មែរកម្ពុជាក្រោមជាច្រើនអង្គមក ហើយដែលត្រូវយួនកុម្មុយនីស្តសម្លាប់ដោយត្រង់ៗ ឬដោយប្រយោល ឬដោយអាថិកំបាំង ឬដោយលក្ខណៈផ្សេងៗ... ការសម្លាប់ខ្មែរកម្ពុជាក្រោមមានច្រើនបែបច្រើនយ៉ាងណាស់តាំងតែពីយើងបាត់ដីកម្ពុជាក្រោមទៅក្នុងកណ្តាប់ដៃយួន ។ អាចរាប់តាំងពីជំនាន់ជីកព្រែកវិញ្ញតេរហូតមកដល់សម័យយៀកមិញរួចបន្តមកដល់សម័យយៀកកុងនឹងក្រោយនេះមកដល់សម័យមួយដែលយួនបានឯករាជបង្រួបបង្រួមទាំងខាងជើងនឹងខាងត្បូងដីកម្ពុជាក្រោម) ឱ្យទៅជាប្រទេសយួនតែមួយមក. ខ្មែរកម្ពុជាក្រោមត្រូវបានយួនសម្លាប់ក្រោមរូបភាពយ៉ាងច្រើនរាប់មិនអស់ទេ។ អ្នកប្រឆាំងនឹងវាពិតជាត្រូវបានវាសម្លាប់ហើយ. អ្នកមិនតាមបង្គាប់វា. ពិតជាត្រូវគេចឱ្យឆាយពីពួកវា. មិនអាចនៅភូមិស្រុកដែលពួកវាអាចចូលមកបាននោះទៀតឡើយ ហេតុនេះហើយទើបខ្មែរកម្ពុជាក្រោមតែងតែភៀសខ្លួនទៅរស់នៅឯប្រទេសកម្ពុជាគ្រប់តែជំនាន់កាល។ ចាប់តាំងពីជំនាន់ដីខ្មែរញាំញីដោយយួន ហេង សំរិន, ហ៊ុន សែន, ជា ស៊ីម មកកម្ពុជាលែងជាទ្រនំសុខសាន្តឱ្យ "បក្សីបាក់ស្លាប" ខ្មែរកម្ពុជាក្រោមទៀតហើយ ។ ព្រោះទឹកដីនេះត្រូវទទួលពីយួននូវមេរៀន "ស្វាបេះដៃគ្នាឯងទម្លាក់ឱ្យខ្លាស៊ី" ដើម្បីបានសុខខ្លួនឯង។ ខ្មែរកម្ពុជាក្រោមរស់ក្នុងភាពជាជនអនាថាចុះទឹកក្រពើឡើងលើខ្លានៅទីណាក៏រងវាសនាត្រូវគេចាប់ហែកស៊ីឥតឈប់ឈរនៅឯកម្ពុជាក្រោមមានងារជាខ្មែរបែរមកស្រុកខ្មែរបែរជាបានងារថាជាយួនទៅវិញ! តែបើសុខចិត្តរស់ក្នុងសំបកជាខ្មែរក្រោមហើយសុខចិត្តបំផ្លាញខ្មែរឱ្យផលចំណេញដល់ប្រយោជន៍យួនវិញ. រស់នៅទីណាក៏បានដែរហើយយួនឱ្យពិន្ទុថា "Good" តែមិនមែនបានសុខរហូតទេណា!, ពេលយួនលែងត្រូវការ ឬពេលគេប្រើមិនបានស្រួលៗទៀតគេចាត់ការតាមរូបភាពផ្សេងៗយ៉ាងសំបូរបែបមានដូចជារបៀបច្បាច់ក្រូចឆ្មាយកអស់ទឹកត្រវាត់សំបកចោលដោយងាយ។ នេះជារូបភាពមួយខ្មែរគ្រប់រូបត្រូវចងចាំ. កុំប្រហែសខ្លួនធ្វើខ្ញុំយួនចុងក្រោយវាសងគុណដូចស្តេច ស៊ីហនុ បានទទួលមិនខាន ឬដូចលោក ប៉ែន សុវ៉ាន់, ចាន់ ស៊ី ជាដើម។ ដោយយល់ថា រឿងយួនសម្លាប់ខ្មែរទាំងក្រោមទាំងលើមានច្រើនមិនអាចរាប់អស់បានក្នុងពេលមួយដ៏ខ្លីយ៉ាងនេះទេ យើងសូមរំលឹកតែការធ្វើឃាត ឬបៀតបៀនលើព្រះសង្ឃខ្មែរពិសេសលើព្រះសង្ឃខ្មែរក្រោមក្នុងពេលថ្មីៗនេះ។





**តទៅលេខក្រោយ**

AccuCare
Home Care Agency
Group Adults Foster Care Program

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
*To be eligibled for GAFC you must:*
- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មាសហែលស្តង់ដា (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀកពាក់ ពេលប្រើបង្គន់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

**ផលប្រយោជន៍ទទួលបាន :**
*Benefits you will get:*
- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed
for Lowell, Lynn, Revere, and Boston

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ១០

## អាចស្រក់ទឹកភ្នែកដោយ...

បន្ទាប់មកនាងក៏ថតរូបនោះ រួចបង្ហោះចូលក្នុងបណ្តាញសង្គម Instagram របស់ខ្លួន ដើម្បីជូនទៅដល់មិត្តប្រុសរបស់នាងដែលមានឈ្មោះថា Divo មុនពេលនាងជួបគ្រោះថ្នាក់ធ្លាក់យន្តហោះបាត់បង់ជីវិត ។

បើតាមការដកស្រង់សម្តីពីឪពុករបស់ Fauzi ដែលនិយាយទាំងទឹកមុខក្រៀមក្រំបានឱ្យដឹងថា "ពេលនេះនាងបានចាកចេញពីពួកយើង ហើយខ្ញុំសង្ឃឹមថា នាងអាចទៅកាន់សុគតិភពតែយ៉ាងណាមិញខ្ញុំសង្ឃឹមថា យើងនឹងទទួលបានសាកសពរបស់នាងក្នុងពេលឆាប់ៗនេះ" ។

គួសបញ្ជាក់ផងដែរថា Fauzi គឺជាអតីតនិស្សិតផ្នែកច្បាប់តែនាងមានក្តីស្រមៃចង់ក្លាយជានារីអាកាចរ ឬអ្នកបម្រើនៅលើយន្តហោះនេះទើបនាងសម្រេចចិត្តចូលធ្វើការបានរយៈពេល២ឆ្នាំហើយ បើគិតត្រឹមថ្ងៃគ្រោះថ្នាក់នេះ ។ រីឯសាកសពរបស់នាង ក៏ត្រូវបានក្រុមអាជ្ញាធររកឃើញហើយ នឹងត្រៀមបញ្ជូនទៅឱ្យក្រុមគ្រួសាររបស់នាង ។

សារមួយនេះ អាចធ្វើឱ្យយើងស្មានដឹងថា ប្រហែលជានាងដឹងថានាងមានគ្រោះថ្នាក់មិនអាចមានជីវិតរស់បន្តទៀតបាននោះ ទើបនាងបានសម្រេចចិត្តសរសេរ និងថតបង្ហោះសារចុងក្រោយបំផុតមួយនេះ ដើម្បីជូនដល់មនុស្សជាទីស្រឡាញ់របស់នាង ។ ហើយក៏មិនមែនតែសាច់ញាតិ និងមនុស្សជិតស្និទ្ធ និងនាងទេ ដែលមានអារម្មណ៍សោកស្តាយ និងក្តុកក្តួលក្នុងចិត្តនោះ មនុស្សជាច្រើន ផ្សេងទៀតក៏សុទ្ធតែមានអារម្មណ៍បែបនេះដែរ នៅពេលដែលបានឃើញសារចុងក្រោយរបស់នាងមួយនេះ ៕

តមកពីទំព័រទី ១៦ វិប្បធមិសន្មា...

បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អនៅក្នុងរដ្ឋសភា ។

ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរាជរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី២៥(ម្ភៃប្រាំ)ភាគរយឡើងទៅមានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា ។ ប្រធានក្រុមមតិភាគតិចជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ ។ ប្រធានក្រុមមតិភាគតិចមានឋានៈស្មើនាយករដ្ឋមន្ត្រី ។

អាសនានុក្រមនៃក្រុមតំណាងរាស្ត្រត្រូវរៀបជាក្រុមៗតាមគណបក្សនយោបាយពីមុខទៅក្រោយ ។ ក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិចដប់រូប ។ តំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗត្រូវមានប្រធានមួយរូបអនុប្រធានមួយរូប ។ គណបក្សនយោបាយណាមានអាសនៈតិចជាងដប់រូបត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ ។ បញ្ជីរាយនាមរបស់ក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយត្រូវផ្ញើជូនប្រធានរដ្ឋសភា ៕

## NOTICE OF PUBLIC MEETING AND COMMENT OPPORTUNITY : 2014 DRAFT COORDINATED HUMAN SERVICES TRANSPORTATION PLAN AND AMENDMENT TO THE 2015 DRAFT TRANSPORTATION IMPROVEMENT PRGARAM

The Northern Middlesex Metropolitan Planning Organization (NMMPO) has released the 2014 Draft Coordinated Human Services Transportation Plan (CHSTP) and the proposed Draft FY 2015 Transportation Improvement Program (TIP) Amendment for public comment. The CHSTP strives to improve mobility for all segments of the population, increase the efficiency of public transit services operated by public, private and non-profit providers, close existing gaps in service, and eliminate duplication of services. The TIP amendment will add Sarbanes Transit in the Park funds for the Lowell Trolley Expansion Project, and will also add Federal Lands Access Program funds for Phase II of the Merrimack Riverwalk extension in Lowell.

Two public meetings will be held to receive comments on the above mentioned documents. The first meeting will take place on January 6th, 2015, 5:30 PM, at the Northern Middlesex Council of Governments (NMCOG) office, located at 40 Church Street, Suite 200, Lowell, MA. The second meeting will be held on January 7th, 2015, 6:00 PM, at the Chelmsford Police Department Meeting Room, 2 Olde North Rd, Chelmsford, MA. You may also submit comments by phone at (978) 454-8021, ext 121, or by email: jhoward-@nmcog.org. Alternatively, comments may also be mailed to NMCOG office at the above address.

The public comment period will end at close of business on January 9th, 2015. You may access a copy of the documents online at www.nmcog.org , or by calling (978) 454-8021.

Notice: The meeting locations are accessible to people with disabilities and near public transportation. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward @nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

## កំណត់ប្រជុំសាធារណៈនិងឱកាសសម្រាប់ផ្តល់យោបល់ :

អង្គការរៀបចំធ្វើផែនការសម្រាប់ទីក្រុងធំក្នុងខណ្ឌ"មីឌលសិច"ភាគខាងជើង (NMMPO) បានចេញពង្រាងឆ្នាំ២០១៤រៀបចំសេវាមនុស្សក្នុងផែនការដឹកជញ្ជូន (CHSTP) ហើយនឹងសំណើរសំរាប់ឆ្នាំ២០១៥ស្តីពីអភិវឌ្ឍន៍ខាងដឹកជញ្ជូន (TIP) សម្រាប់ជូនសាធារណជនផ្តល់យោបល់ធ្វើវិសោធនកម្ម ។ កម្មវិធី CHSTP ខំព្យាយាមធ្វើឱ្យការធ្វើដំណើររបស់គ្រប់ភាគនៃប្រជាពលរដ្ឋរីតតែប្រសើឡើងបង្កើនប្រសិទ្ធភាពនៃសេវាឆ្លងកាត់សាធារណៈដែលដើរបានដោយអ្នកផ្តល់សេវា គឺជាសាធារណជនជាឯកជន ឬជាអង្គការមិនយកកម្រៃយ៉ាងនេះ គឺបន្ថយនូវកង្វះសេវាដែលកំពុងមាន នឹងបំបាត់សេវាដែលជួនគ្នាទៀតផង ។ វិសោធនកម្មរបស់ TIP នឹងបន្ថែមចំណត Sabanes នៅក្នុងថវិការរបស់ឧទ្យានសម្រាប់គម្រោងពង្រីករថភ្លើងក្រុងនៅឡូវែល ហើយជាមួយគ្នានេះដែរ នឹងបន្ថែមថវិការក្នុងកម្មវិធីដីធ្លីសហព័ន្ធសម្រាប់រយៈកាលទី២ នៃការពង្រីកផ្លូវដើរតាមដងទន្លេមេរីម៉ាកនៅឡូវែល ។

នឹងមានកិច្ចប្រជុំសាធារណ២ដងដែលរៀបចំឡើងសម្រាប់ទទួលយោបល់សម្រាប់ឯកសាររៀបរាប់ខាងលើ :

- កិច្ចប្រជុំទី១ថ្ងៃទី ០៦ មករា ២០១៥ ម៉ោង ៥កន្លះល្ងាច នៅ NMCOG 40 Church St.Suite 200 Lowell, MA
- កិច្ចប្រជុំទី២ ថ្ងៃទី ០៧ មករា២០១៥ ម៉ោង៦ល្ងាច នៅសាលប្រជុំប៉ូលិស 2olde North Rd. Chelmford, MA

លោកអ្នកអាចផ្តល់យោបល់តាមទូរស័ព្ទលេខ 978-454 80 21 បន្ត 121 ឬក៏អ៊ីមែលទៅ jhoward @nmcog.org ឬក៏សរសេរយោបល់លោកអ្នករួចផ្ញើរសំបុត្រទៅ NMCOG នៅអស័យដ្ឋានដូចខាងលើរយៈពេលផ្តល់យោបល់សាធារណៈនឹងត្រូវផុតកំណត់នៅថ្ងៃ០៩ មករា២០១៥

លោកអ្នកអាចចូលទៅរកឯកសារតាម "អ៊ិនឡាញ" នៅ www.NMCOG.org ឬទូរស័ព្ទទៅ 978- 454 8021

**កំណត់ចំណាំ :** ទីកន្លែងប្រជុំនេះ ផ្តល់ភាពងាយស្រួលដល់ជនពិការពីព្រោះស្ថិតនៅក្បែរ ផ្លូវដឹកជញ្ជូនសាធារណៈ ។ NMCOG ផ្តល់ជូនលោកអ្នកនូវការស្នាក់ អាស្រ័យសមរម្យនឹងការជួយដល់ការយល់ភាសាដោយឥតគិតថ្លៃតាមការស្នើសុំ (ដោយរាប់ទាំង ប៉ុន្តែមិនកំណត់ត្រឹមអ្នកបកប្រែភាសាតាមកាយវិការ ឬបកប្រែភាសាផ្សេងពីភាសាអង់គ្លេសបើកនឹងបិទចំណងជើងវីដេអូជួយដល់ការស្តាប់ដោយឧបករណ៍សម្លេងនឹងសម្ភារៈជំនួសផ្សេងទៀតដែលយើងមាន ។

សូមទាក់ទងដើម្បីរកជំនួយទៅ ជូស្ទីន ហូវើដទូរស័ព្ទ 978- 4548021 បន្តរទៅ 121 ឬអ៊ីម៉ែល jhoward @nmcog.org សូមស្នើសុំមកយើងឱ្យបានឆាប់ ដើម្បីឱ្យយើងអាចរៀបចំជូនឱ្យទាន់ពេលវេលានេះរាប់ទាំងភាសាកាយវិការ រទេះពិការ ឬបកប្រែឯកសារ ឬបកប្រែភាសា ៕

# CLASSIFIED ADS

**CALL: 978.677.7163**

EMAIL: SOBENPIN@KHMERPOST.US

## ចំពោះអ្នករកការងារធ្វើ

មជ្ឈមណ្ឌលសុខភាព CBC មានការងារ ជូនអ្នកថែអ្នកជំងឺ Nurse practitioners និង វេជ្ជបណ្ឌិត Physicians ពេញពេល ឬតិចជាង -ប្រាក់បៀវត្សមិនចាញ់គេនឹងមានផលចំណេញ ដ៏មានប្រយោជន៍ផ្សេងទៀត ។ សូមបញ្ជូនប្រវត្តិរូបសង្ខេបទៅ

kdilwali@bellericamedican.com

## ជាវសៀវភៅតាមកាសែតខ្មែរប៉ុស្តិ៍ស.រ.អា



រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៤៥ តម្លៃ $10




CAMBODGE តម្លៃ $5



អង្គការជានរណា? ២ភាគ តម្លៃ $5/1

សូមកាត់ត្រង់នេះផ្ញើមកយើង

| | |
|---|---|
| អាសយដ្ឋានយើង៖ 45 Merrimack St., Suite 218A, Lowell, MA 01852 | ឈ្មោះសៀវភៅបញ្ជាទិញ តម្លៃ$........ |
| ឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នក | តម្លៃ$........ |
| អាសយដ្ឋាន | ចំនួនសៀវភៅសរុប: |
| ក្រុង, រដ្ឋ, ហ្ស៊ីបកូដ | ថ្លៃសៀវភៅសរុប តម្លៃសរុប$................ |

ទូរស័ព្ទ/ អ៊ីម៉ែល:

សូមផ្ញើជា Check ឬ Money order ទៅ KhmerPostUSA នៅអាសយដ្ឋានខាងលើ




# សូឱ្យមានមិត្តច្រើនជាជាងបង្កើនសត្រូវច្រើន

•••ពាក្យថា "មិត្ត" មានន័យដូចគ្នានឹងពាក្យថា "សម្លាញ់, ភ្លើ និងពួកម៉ាកពាក្យប៉ុន្មានម៉ាត់នេះមានន័យប្រហាក់ប្រហែលគ្នា ក៏ពិតមែន ប៉ុន្តែតាមធម្មតាពាក្យមិត្តបានបញ្ជាក់យ៉ាងច្បាស់ពីទម្ងន់នៃអត្ថន័យខ្លឹមសារ ដូចជាពាក្យថា កល្យាណមិត្ត និងបាបមិត្តដោយសំដៅទៅលើមិត្តដែលមានអាធ្យាស្រ័យល្អប្រពៃ និងមិត្តដែលមានអាធ្យាស្រ័យអាក្រក់ស្មោគគ្រោកស្មើនឹងពាក្យថា សត្រូវ ឬបច្ចាមិត្តនោះដែរ ។

នៅពេលយើងយល់ និងដឹងច្បាស់ពីអត្ថន័យនៃពាក្យថា មិត្តរួចហើយ វាជាការងាយយល់ណាស់ អំពីពាក្យថា សត្រូវដែលមានអត្ថន័យថាអ្នកបៀតបៀនគេ អ្នកប្រទូសរ៉ាយគេចងទោស ឬចងគំនំគំគួន រករឿងគ្នា ដូចគ្នានឹងពាក្យថា បច្ចាមិត្តនោះដែរ ។

ក្រោយពីបានយល់នឹងដឹងអំពីពាក្យថា មិត្ត និងសត្រូវនេះហើយ ទើបបណ្តាលឱ្យមនុស្សដែលស្ថិតនៅក្នុងពេលប្រជុំជនជូននេះ ត្រូវតែមានវិចារណញ្ញាណ ចេះគិតគូត្រិះរិះពិចារណាភាវរកឱ្យបានរកឃើញនូវមនុស្សជាទីពឹងពុំនាក់សម្រាប់ជួយដោះស្រាយក្នុងគ្រប់បញ្ហាវិបត្តិធំតូចក្តីឱ្យបានរួចជ្រះស្រឡះល្អប្រសើរឡើងវិញ ទៅតាមរយៈមនុស្សដូចគ្នាដែលមានសមានចិត្តពោរពេញទៅដោយសុច្ចរិតធម៌ សប្បុរសធម៌ ស្មោះត្រង់ និងយុត្តិធម៌ពិតប្រាកដ ។

មនុស្សដែលបានចេញមុខមកជួយដោះស្រាយបញ្ហានោះហើយ ដែលមានឈ្មោះថា មិត្ត ឬកល្យាណមិត្តនោះ ។ ពីព្រោះនៅពេលណាដែលមានបញ្ហាវិបត្តិកើតឡើង គឺពិតជាមនុស្សអ្នកបង្កើតដោយខ្លួនឯង រួចហើយអ្នកបង្កើតនោះពុំអាចមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះខ្លួនឯងនោះសោះឡើយ ។

បើសិនជាគេបង្កើតបញ្ហាវិបត្តិដ៏មានគ្រោះថ្នាក់ខ្លាំងក្លានោះ នៅតែព្យាយាមក្រាញនឿលចចេសរឹងរូស មិនព្រមលើកបញ្ហាវិបត្តិនោះ ទៅឱ្យអ្នកដទៃជួយដោះស្រាយទេនោះ មានន័យថាមិនព្រមផ្ទេរមុខនាទីរបស់ខ្លួនទៅឱ្យអ្នកដទៃផ្សេងទៀតទេនោះ វាពិតជាពុំអាចដោះស្រាយបានឡើយ ហើយបញ្ហាវិបត្តិក៏កាន់តែរីកធំឡើងៗជាលំដាប់ រហូតដល់ថ្ងៃដែលត្រូវធ្លាក់ទៅក្នុងសេចក្តីវិនាសហិនហោចអន្តរធានគ្មានសល់អ្វីឡើយ ។


**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

**$50** ក្នុង១ខែ

*CALL:*
*978.677.7163*

*EMAIL: SOBENPIN@KHMERPOST.US*

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.


បញ្ហាវិបត្តិតូចក្តីធំក្តីវាតែងតែកើនមាននៅក្នុងសង្គមមនុស្សតាំងពីសង្គមតូចគ្រួសារ រហូតដល់សង្គមធំជាតិទាំងមូលតែម្តងដែលមានមូលហេតុបណ្តាលមកពីមនុស្សជាអ្នកបង្កើត ក៏មានដូចជាជម្លោះទាស់ទែងគ្នាការរំលោភបំពានលើសិទ្ធិសេរីភាពគ្នាការកេងប្រវ័ញ្ចលួចបន្លំគ្នាការធ្វើបាបសង្កត់សង្កិនគ្នាជាដើម និងម្យ៉ាងទៀតមកពីធម្មជាតិជាអ្នកបង្កើត ក៏មានដូចជាគ្រោះថ្នាក់ធម្មជាតិនានា មានទឹកជំនន់ អគ្គិភ័យ រញ្ជួយផែនដី ព្យុះសង្ឃរាលើ ដីគោក

**តទៅលេខក្រោយ**

# បាញ់ទឹកអប់ដូចម្ដេច ទើបក្លិនក្រអូបបានយូរ





ទឹកអប់ជាគ្រឿងបន្ថែមក្លិនក្រអូបដល់រាងកាយដែលជាទីចាប់ចិត្តចង់ហិតក្លិនម្ចាស់កាយចង់កៀកកើយនៅក្បែរជានិច្ច ។ ប៉ុន្ដែថា តើគួរត្រូវធ្វើយ៉ាងណាដើម្បីរក្សាក្លិនក្រអូបបានយូរ ?

ទឹកអប់នឹងសាយក្លិននៅក្នុងអាកាសធាតុបានល្អនៅពេលស្ថិតនៅលើស្បែកក្ដៅឧណ្ហៗ ដែលមានសរសៃឈាមហូរចុះឡើង ដូចជា កញ្ចឹង.ក កដៃផ្នែកខាងក្នុងសន្លាក់ទាំងឡាយ រួមទាំងជង្គង់ក្រលៀន ចង្កេះទ្រូង និងកជើង ពីព្រោះបរិវេណទាំងនេះមានស្បែកក្ដៅឧណ្ហៗ ជាងបរិវេណផ្សេងៗ ហើយប្រសិនបើចង់ឱ្យក្រអូបដូចក្លិនខ្លួននោះ សាកល្បងបាញ់ទឹកអប់លើក្រាស់សិតសក់បាញ់ក្នុងចម្ងាយល្មម ឱ្យក្លិនតំណក់ទឹកអប់ចាប់ជាប់នឹងក្រាស់ទើបសិតសក់ជាក្រោយ ។ ប៉ុន្ដែជាតិអាល់កុល និងសារធាតុផ្សេងៗក្នុងទឹកអប់អាចធ្វើឱ្យសក់ខូចបានហេតុដូចនេះត្រូវឧស្សាហ៍ថែសក់ជាប្រចាំផង ។

សម្រាប់ស្ត្រីវ័យសិក្សា ឬយុវវ័យទាំងឡាយ សូមណែនាំឱ្យសាកល្បងប្ដូរមកបន្ថែមក្លិនក្រអូបក្នុងកាបូប ឬកន្សែងដៃជំនួសវិញ ដោយយករបស់ដែលមានក្លិនក្រអូបមកដាក់រួមក្នុងប្រអប់មួយ ហើយបាញ់ទឹកអប់ដាក់ដុំសំឡីទៅក្នុងប្រអប់នោះ ក្លិនទឹកអប់របស់អ្នកនឹងរក្សាបានយូរបំផុត ។ វិធីនេះប្រើបានផងដែរជាមួយខោអាវសំលៀកបំពាក់ក្នុងទូល្អជាងការប្រោះព្រំទឹកអប់លើខោអាវ ព្រោះអាចធ្វើឱ្យមានស្នាមលើសំលៀកបំពាក់បាន ។

ចំណែកវិធីថែរក្សាទឹកអប់មិនឱ្យមានក្លិនប្លែកខុសប្រក្រតី គួរទុកដាក់ទឹកអប់ក្នុងកន្លែងដែលត្រជាក់តែមិនមានសំណើម និងមិនត្រូវកម្ដៅថ្ងៃខ្លាំង បើចង់ទុកដាក់ឱ្យបានល្អនោះ អាចដាក់ក្នុងប្រអប់សុញ្ញាកាសក៏បាន ៕


LOWELL ELDER CARE 978-596-1111

## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយ ដែលផ្ដល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

### មណ្ឌលផ្ដល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្ដៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips





**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# KhmerPost USA

## The Cambodian-American Biweekly Newspaper
សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីសប្តាហ៍ម្តង

**Soben Pin, Managing Partner** អ្នកគ្រប់គ្រង សុបិន្ត ពិន

**978.677.7163 (Office) 978. 656.8141 (Mobile)**

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

**Reserve Your 2015 Ads with us today and receive up to 20% OFF!**

## Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ<br>Page Size | ប្រវែង<br>Length x Width | 1ខែ<br>1 month<br>10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/4 Classify Ad | (6.5"x5") | $160 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

## Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| January | 2th & 23rd |
| February | 6th & 20th |
| March | 6th & 20th |
| April | 3rd & 24th |

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA





# រមណីយដ្ឋានកូនភ្លោះធម្មជាតិ ដ៏ស្រស់ត្រកាល ភ្នំបាក់ ភ្នំជញ្ជាំង



ភ្នំបាក់ និង ភ្នំជញ្ជាំង ជារមណីដ្ឋានធម្មជាតិ និងវប្បធម៌មួយដ៏ស្រស់ត្រកាលដែលមានទីតាំង នៅក្នុងស្រុកសិរីសោភ័ណមានចម្ងាយ៩គីឡូម៉ែត្រ ពីទីរួមខេត្តបន្ទាយមានជ័យ។ ភ្នំបាក់ និងភ្នំជញ្ជាំង ជាកន្លែងកំសាន្តមួយដែលមានភ្នំពីរនៅជិតគ្នាដែលមើលទៅមានរូបរាង និងមានឈ្មោះដូចជាកូនភ្លោះ មានថ្មធំៗ ជាច្រើនបញ្ឈរ ដូចជាជញ្ជាំង ពោរពេញ ដោយ បរិយាកាស និងទិដ្ឋភាពដ៏ល្អប្រណិត។ ចំណែកនៅចន្លោះភ្នំមានកន្លែងដ៏ស្រស់ស្អាតមួយសំរាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិសំរាកកំសាន្ត។ ជាពិសេសនៅជើងភ្នំមានត្រពាំងធំមួយមានទំហំ១០ម៉ែត្រការ៉េ ជម្រៅ១២ម៉ែត្រ និង រូបចម្លាក់ថ្មបុរាណជាច្រើនបានធ្លាក់សន្សល់ទុកនៅក្នុងត្រពាំងនោះ តាំងពីសម័យមុនមកម្ល៉េះ។ សូមទស្សនា រូបភាពខាងលើ !!!







# តំបន់ទេសចរណ៍ធម្មជាតិ ជម្រកសត្វព្រៃភ្នំណាំលៀវ



ជម្រកសត្វព្រៃភ្នំណាំលៀវ ជាតំបន់ទេសចរណ៍ដ៏ស្រស់ស្អាត សម្បូរណ៍ទៅដោយ ព្រៃភ្នំនិង សត្វព្រៃជាច្រើន ប្រភេទ រស់នៅក្នុងតំបន់នេះ ដែលមានផ្ទៃដីទំហំ៤៧៥គីឡូម៉ែត្រការ៉េ ចម្ងាយ៤៥គីឡូម៉ែត្រពីទីរួមខេត្តមណ្ឌលគិរី។ ជម្រកសត្វព្រៃភ្នំណាំលៀវនេះគឺជាកន្លែងរក្សាទុកសត្វព្រៃដ៏សំខាន់មួយនៅក្នុងខេត្តមណ្ឌលគិរី ដែលពោរពេញ ដោយព្រៃព្រឹក្សា និងសត្វព្រៃដ៏ស្រស់ស្អាត និងទាក់ទាញបំផុត សំរាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ ភ្ញៀវទេសចរណ៍ភាគច្រើនចូលចិត្តកំសាន្តនៅជម្រកសត្វព្រៃនេះ រីករាយនឹងការដើរទស្សនា សម្រស់ព្រៃឈើធម្មជាតិព្រៃសត្វ ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងជិះដំរីឡើងភ្នំ។ សូមទស្សនារូបភាពខាងក្រោម !!!